ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នាយកដ្ឋានថវិកា

# គោលការណ៍ណែនាំ
# ស្តីពី
# ការដាក់ឲ្យអនុវត្ត
# សាកល្បងអង្គភាពថវិកា

**ខែមីនា ឆ្នាំ២០១៣**

មាតិកា

**១. សេចក្តីផ្តើម** ..................... 3
១.១ សាវតា ..................... 4
១.២ គោលបំណង ..................... 5
**២. ក្របខណ្ឌអង្គភាពថវិកា** ..................... 5
២.១ និយមន័យនៃអង្គភាពថវិកា ..................... 5
ដ្យាក្រាមទី១ រចនាសម្ព័ន្ធគ្រប់គ្រងក្រសួង ស្ថាប័ន ..................... 6
២.២ អត្ថប្រយោជន៍នៃអង្គភាពថវិកា ..................... 7
**៣. នីតិវិធីក្នុងការរៀបចំអង្គភាពថវិកា** ..................... 9
៣.១ ជំហានទី១ ការពិនិត្យលើបេសកកម្ម អាណត្តិកិច្ច និងគោលបំណងគោលនយោបាយ ..................... 9
៣.២ ជំហានទី២ ការពិនិត្យលើរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័នបច្ចុប្បន្ន ..................... 10
៣.៣ ជំហានទី៣ ការពិនិត្យ និងវាយតម្លៃលើអង្គភាពដែលអាចក្លាយជាអង្គភាពថវិកា ..................... 11
៣.៤ ជំហានទី៤ ការរៀបចំបង្កើតអង្គភាពថវិកា ..................... 12
៣.៥ ជំហានទី៥ ការរៀបចំ និងអនុម័តលើរបាយការណ៍ស្តីពីការរៀបចំអង្គភាពថវិកា ..................... 13
៣.៦ ជំហានទី៦ ការត្រួតពិនិត្យ និងឯកភាពលើសំណើបង្កើតអង្គភាពថវិកា ..................... 13
**៤. ការដាក់ឲ្យអនុវត្តអង្គភាពថវិកា** ..................... 14
៤.១ យុទ្ធសាស្រ្តនៃការដាក់ឲ្យអនុវត្តអង្គភាពថវិកា ..................... 14
៤.២ ផែនការសកម្មភាពដើម្បីដាក់ឲ្យអនុវត្តអង្គភាពថវិកា ..................... 15
**ឧបសម្ព័ន១ តារាងសម្រាប់ក្រសួង ស្ថាប័នបំពេញតាមជំហាននីមួយៗ** ..................... 17
តារាងទី១ រចនាសម្ព័ន្ធគោលនយោបាយរបស់ក្រសួង ស្ថាប័ន ..................... 18
តារាងទី២ រចនាសម្ព័ន្ធគ្រប់គ្រងក្រសួង ស្ថាប័ន ..................... 19
តារាងទី៣ ការផ្សារភ្ជាប់រចនាសម្ព័ន្ធគ្រប់គ្រងទៅនឹងរចនាសម្ព័ន្ធគោលនយោបាយរបស់ក្រសួង ស្ថាប័ន ...20
តារាងទី៤ ការវាយតម្លៃតាមលក្ខខណ្ឌវិនិច្ឆ័យអង្គភាពថវិកា ..................... 21
តារាងទី៥ ការរៀបចំផែនការសកម្មភាពសម្រាប់កែលម្អ ..................... 25
តារាងទី៦ របាយការណ៍ស្តីពីការស្នើសុំអង្គភាពថវិការបស់ក្រសួង ស្ថាប័ន ..................... 27
**ឧបសម្ព័ន្ធ២ ក្របខណ្ឌនៃការទទួលខុសត្រូវរវាងនាយកដ្ឋានហិរញ្ញវត្ថុ និងអង្គភាពថវិកា** ..................... 30

## ១. សេចក្តីផ្តើម

គោលការណ៍ណែនាំនេះ មានគោលបំណងផ្តល់នូវការណែនាំដល់ក្រសួងដែលនឹងត្រូវចូលរួមសាកល្បងទាំង១០ អំពីការរៀបចំរចនាសម្ព័ន្ធអង្គភាពថវិកាថ្មី ដើម្បីជាមូលដ្ឋានសម្រាប់រៀបចំផែនការយុទ្ធសាស្រ្តថវិកា និងសម្រាប់រៀបចំថវិកាប្រចាំឆ្នាំ។ ការអនុវត្តក្របខណ្ឌអង្គភាពថវិកា គឺជាសកម្មភាពចម្បងមួយក្នុងចំណោមសកម្មភាពចម្បងនានា សម្រាប់លើកកម្ពស់គណនេយ្យភាពហិរញ្ញវត្ថុដែលជាចំណុចសំខាន់នៅក្នុងជំហានទី២នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការអនុវត្តក្របខណ្ឌអង្គភាពថវិកានឹងធ្វើឲ្យការបែងចែកមុខងារ ភារកិច្ច និងការទទួលខុសត្រូវ កាន់តែមានភាពច្បាស់លាស់ ពិសេសរវាងនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ (អ្នកគ្រប់គ្រងថវិកា) និងនាយកដ្ឋានជំនាញឬអង្គភាពផ្តល់សេវាសាធារណៈ (អ្នកប្រើប្រាស់ និងអ្នកអនុវត្តថវិកា)។ ទន្ទឹមនឹងនេះ នឹងអាចបង្កើនគណនេយ្យភាពសមិទ្ធកម្ម និងប្រសិទ្ធិភាព និងភាពស័ក្តសិទ្ធិក្នុងការគ្រប់គ្រង និងការអនុវត្តសកម្មភាពការងាររបស់ក្រសួង ស្ថាប័ន។ ដើម្បីសម្រេចបានតាមគោលដៅខាងលើ គោលការណ៍ណែនាំនេះត្រូវបានរៀបចំឡើងនូវនីតិវិធីជាជំហានៗសម្រាប់ក្រសួង ស្ថាប័នធ្វើជាមូលដ្ឋានក្នុងការរៀបចំរចនាសម្ព័ន្ធអង្គភាពថវិការបស់ខ្លួន។ ជំហាននីមួយៗត្រូវបានរៀបចំឡើងសម្រាប់ជាមូលដ្ឋានក្នុងការរៀបចំជំហានបន្តបន្ទាប់។ ជំហានទាំងនេះ គឺត្រូវចាប់ផ្តើមពីកម្រិតនៃការពិនិត្យឡើងវិញលើបេសកកម្មអាណត្តិកិច្ច និងគោលបំណងគោលនយោបាយនៃក្រសួង ស្ថាប័ននីមួយៗ ដែលជាមូលដ្ឋានក្នុងការរៀបចំជំហានទី២ គឺការពិនិត្យមើលរចនាសម្ព័ន្ធគ្រប់គ្រងបច្ចុប្បន្ន ហើយជាបន្តបន្ទាប់រហូតដល់ជំហានចុងក្រោយគឺការត្រួតពិនិត្យមើល និងឯកភាពលើរចនាសម្ព័ន្ធអង្គភាពថវិកាពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រចនាសម្ព័ន្ធនៃអង្គភាពថវិកាដែលត្រូវបានរៀបចំខាងលើនឹងត្រូវយកមកប្រើប្រាស់សម្រាប់ការរៀបចំ ការអនុវត្ត និងការតាមដានថវិកា ទៅតាមយុទ្ធសាស្ត្រដែលបានរៀបចំឡើងជា៣ដំណាក់កាល គឺការរៀបចំ និងដាក់ឲ្យអនុវត្តសាកល្បងដែលជាដំណាក់កាលទី១ ហើយបន្ទាប់មកគឺការពង្រឹង និងពង្រីកការអនុវត្តអង្គភាពថវិកាដែលជាដំណាក់កាលទី២ និងដំណាក់កាលចុងក្រោយ គឺការឈានទៅអនុវត្តពេញលេញនៃអង្គភាពថវិកានៅគ្រប់ក្រសួង ស្ថាប័ន។

ការដាក់ឲ្យអនុវត្តសាកល្បងនៃដំណាក់កាលទី១ នឹងចាប់ផ្តើមក្នុងពេលរៀបចំថវិកាឆ្នាំ២០១៥ ជាមួយក្រសួងសាកល្បងចំនួន១០ ទន្ទឹមគ្នានឹងការដាក់ឲ្យអនុវត្តនូវដំណាក់កាលទី១នៃប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ទោះជាការដាក់ឲ្យអនុវត្តសាកល្បងនូវក្របខ័ណ្ឌអង្គភាពថវិកាដំណាក់កាលទី១នៅក្នុងឆ្នាំ២០១៥ក៏ដោយ ក្នុងការរៀបចំថវិកាឆ្នាំ២០១៤ រាជរដ្ឋាភិបាលនឹងតម្រូវឲ្យគ្រប់ក្រសួង ស្ថាប័នទាំងអស់ វិភាជថវិការបស់ខ្លួនដល់កម្រិតនាយកដ្ឋាន (កម្រិតអនុវត្តសកម្មភាព) គឺកម្រិតទី៣ ដែលបានកំណត់នៅក្នុងរចនាសម្ព័ន្ធអង្គភាពថវិកា។ ធ្វើបែបនេះ គឺដើម្បីឲ្យក្រសួង ស្ថាប័នទាំងអស់អាចចាប់ផ្តើមត្រៀមលក្ខណៈជាបណ្តើរៗ ក្នុងការអនុវត្តយុទ្ធសាស្ត្រជាដំណាក់កាលនៃការដាក់ឲ្យអនុវត្តអង្គភាពថវិកាឲ្យបានជោគជ័យតាមការគ្រោងទុក។ បន្ទាប់មក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងធ្វើការវាយតម្លៃពីលទ្ធផល និងបទពិសោធន៍នៃការអនុវត្តសាកល្បងនោះនៅក្នុងឆ្នាំ២០១៦ ឬ២០១៧ បន្ទាប់ពីដាក់ឲ្យអនុវត្តសាកល្បងនៅក្នុងឆ្នាំ២០១៥។ លទ្ធផល និងបទពិសោធន៍ទាំងនោះនឹងត្រូវយកមកសម្រាប់រៀបចំយុទ្ធសាស្ត្រពង្រឹង

និងពង្រីកការអនុវត្តក្របខណ្ឌអង្គភាពថវិកានៅក្នុងឆ្នាំ២០១៧ និងដើម្បីអាចឈានទៅដាក់ឲ្យអនុវត្តពេញលេញនៅគ្រប់ក្រសួង ស្ថាប័នក្នុងឆ្នាំ២០១៨ ឬ២០២០។

## ១.១ សាវតា

រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាបណ្តើរៗឈានទៅរកស្តង់ដារអន្តរជាតិ តាមរយៈការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាកម្មវិធីមានលក្ខណៈគ្រប់ជ្រុងជ្រោយ មានរយៈពេលវែង និងអនុវត្តតាមអភិក្រម៤ដំណាក់កាលគឺ (១)ដំណាក់កាលនៃការបង្កើនភាពជឿទុកចិត្តលើថវិកា (២)ដំណាក់កាលនៃការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ (៣)ដំណាក់កាលនៃការបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និង(៤)ដំណាក់កាលនៃការបង្កើនគណនេយ្យភាពចំពោះសមិទ្ធកម្ម។

បន្ទាប់ពីបានអនុវត្តដំណាក់កាលទី១ នៃការបង្កើនភាពជឿទុកចិត្តលើថវិកាប្រកបដោយជោគជ័យ ចាប់ពីចុងឆ្នាំ២០០៤ រហូតមកដល់ចុងឆ្នាំ២០០៨ ដែលបានធ្វើឲ្យចំណូលមានការកើនឡើងជាលំដាប់ ការអនុវត្តចំណាយកាន់តែមានភាពរលូន និងលុបបំបាត់បានទាំងស្រុងនូវប្រពៃណីខ្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ ព្រមទាំងលុបបំបាត់បាននូវបំណុលសាច់ប្រាក់ទាំងស្រុង រាជរដ្ឋាភិបាល បានប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការនូវដំណាក់កាលទី២ នៅចុងឆ្នាំ២០០៨។ ក្នុងគោលដៅបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ការរៀបចំអង្គភាពថវិកា គឺជាសកម្មភាពគន្លឹះមួយក្នុងចំណោមសកម្មភាពគន្លឹះសំខាន់ៗទាំង៧ ដែលរួមមាន៖ (១)ការរៀបចំ និងការអនុវត្តអង្គភាពថវិកា (២)ការរៀបចំ និងការអនុវត្តមាតិកាថវិកា និងប្លង់គណនីថ្មី (៣)ការរៀបចំ និងការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុដោយប្រព័ន្ធព័ត៌មានវិទ្យា (៤)ការរៀបចំ និងការអនុវត្តក្របខ័ណ្ឌត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រសួង ស្ថាប័ន (៥)ការរៀបចំ និងការកំណត់ស្តង់ដារគណនេយ្យ (៦)ការកែលម្អឧបករណ៍ដែលជំរុញឲ្យមានការទទួលខុសត្រូវចំពោះការគ្រប់គ្រងហិរញ្ញវត្ថុ និង(៧)ការពង្រឹង និងការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រវិសហមជ្ឈការ និងវិមជ្ឈការហិរញ្ញវត្ថុ ដែលសុទ្ធសឹងជាសកម្មភាពបាននិងកំពុងផ្តោតការយកចិត្តទុកដាក់នៅក្នុងដំណាក់កាលទី២នេះ។

ដើម្បីអនុវត្តតាមគោលដៅខាងលើ នៅឆ្នាំ២០១១ នាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំឯកសារក្របខណ្ឌស្តីពីការរៀបចំអង្គភាពថវិកា ដែលជាមូលដ្ឋានសម្រាប់ការរៀបចំរចនាសម្ព័ន្ធអង្គភាពថវិកានៅតាមក្រសួង ស្ថាប័ន ហើយត្រូវបានអនុម័តដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងខែកុម្ភៈ ឆ្នាំ២០១២។ បន្ទាប់ពីការអនុម័ត និងការប្រឹក្សាលើក្របខណ្ឌស្តីពីការរៀបចំអង្គភាពថវិកាជាមួយក្រសួង ស្ថាប័នរួចមក នាយកដ្ឋានថវិកាបានឈានទៅរៀបចំគោលការណ៍ណែនាំនេះ (គោលការណ៍ណែនាំស្តីពីការដាក់ឲ្យអនុវត្តសាកល្បងក្របខណ្ឌអង្គភាពថវិកា) ដើម្បីជាមូលដ្ឋានសម្រាប់ការដាក់ឲ្យអនុវត្តសាកល្បងជាមួយក្រសួង១០ នៅក្នុងឆ្នាំ២០១៥។ ដូច្នេះ គោលការណ៍ណែនាំនេះរួមមាន ការបញ្ជាក់អំពីក្របខ័ណ្ឌអង្គភាពថវិកា ដែលជាមូលដ្ឋានសម្រាប់ការរៀបចំរចនាសម្ព័ន្ធអង្គភាពថវិការបស់ក្រសួង ស្ថាប័ន នីតិវិធីជាជំហានៗសម្រាប់ណែនាំដល់ក្រសួង ស្ថាប័នក្នុងការរៀបចំអង្គភាពថវិកា ព្រមទាំងយុទ្ធសាស្ត្រ និងផែនការសកម្មភាពលម្អិតសម្រាប់ការដាក់ឲ្យអនុវត្តសាកល្បងអង្គភាពថវិកា។ គោលការណ៍ណែនាំនេះ នឹងត្រូវដាក់ជូនគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញ

វត្ថុសាធារណៈអនុម័ត មុននឹងរាជរដ្ឋាភិបាលចេញអនុក្រឹត្យដាក់ឲ្យអនុវត្តសាកល្បងជាផ្លូវការសម្រាប់ការរៀបចំថវិកាឆ្នាំ២០១៥។

### ១.២ គោលបំណង

គោលការណ៍ណែនាំនេះ ពិតជាអាចផ្តល់មូលដ្ឋានដ៏សំខាន់ដល់គ្រប់ក្រសួង ស្ថាប័ន សម្រាប់ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័នប្រកបដោយភាពស័ក្តិសិទ្ធិ ពិសេស ចំពោះក្រសួង ស្ថាប័នដែលមានគោលដៅក្នុងការពង្រឹងការគ្រប់គ្រងថវិការបស់ខ្លួន ឆ្ពោះទៅរកប្រព័ន្ធថវិកាផ្តោតលើលទ្ធផល។ ទោះជាយ៉ាងនេះក៏ដោយ គោលការណ៍ណែនាំនេះ ផ្តោតជាសំខាន់សម្រាប់ចង្អុលបង្ហាញដល់ក្រសួងសាកល្បងទាំង១០ ក្នុងការរៀបចំរចនាសម្ព័ន្ធអង្គភាពថវិការបស់ខ្លួនដើម្បីត្រៀមអនុវត្តសាកល្បងនៅក្នុងឆ្នាំ២០១៥។ ដើម្បីសម្រេចបានតាមគោលបំណងខាងលើ គោលការណ៍ណែនាំនេះត្រូវបានចែកជា៤ ផ្នែកដូចខាងក្រោម៖

១. **សេចក្តីផ្តើម:** ពណ៌នាសង្ខេបអំពីគោលបំណងអត្ថប្រយោជន៍ នីតិវិធី ព្រមទាំងយុទ្ធសាស្ត្រនៃការអនុវត្តអង្គភាពថវិកា

២. **ក្របខ័ណ្ឌអង្គភាពថវិកា:** ពណ៌នាសង្ខេបអំពីនិយមន័យ និងអត្ថប្រយោជន៍នៃអង្គភាពថវិកា

៣. **នីតិវិធីសម្រាប់ការរៀបចំអង្គភាពថវិកា:** ពណ៌នាសង្ខេបអំពីនីតិវិធីជាជំហានៗ សម្រាប់ការរៀបចំអង្គភាពថវិកា ដើម្បីអនុវត្តដែលរួមមាន៖ ជំហានទី១: ការពិនិត្យលើបេសកកម្ម អាណត្តិកិច្ច និងគោលបំណងគោលនយោបាយ ជំហានទី២: ការពិនិត្យលើរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័នបច្ចុប្បន្ន ជំហានទី៣: ការពិនិត្យ និងវាយតម្លៃលើអង្គភាពដែលអាចក្លាយជាអង្គភាពថវិកា ជំហានទី៤: ការរៀបចំបង្កើតអង្គភាពថវិកា ជំហានទី៥: ការរៀបចំ និងអនុម័តលើរបាយការណ៍ស្តីពីការរៀបចំអង្គភាពថវិកា និងជំហានទី៦: ការត្រួតពិនិត្យ និងឯកភាពលើសំណើបង្កើតអង្គភាពថវិកា

៤. **យុទ្ធសាស្ត្រ និងផែនការសកម្មភាព:** ពណ៌នាសង្ខេបអំពីគោលបំណងនៃគម្រោងសាកល្បង និងយុទ្ធសាស្ត្រសម្រាប់អនុវត្តរចនាសម្ព័ន្ធអង្គភាពថវិកាទាំងនៅក្នុងក្រសួងសាកល្បង និងសម្រាប់គ្រប់ក្រសួងនៅរយៈពេលវែង។ ផ្នែកនេះក៏ពណ៌នាផងដែរអំពីបុរេលក្ខខណ្ឌមួយចំនួនដែលក្រសួងសាកល្បងនីមួយៗគួរបំពេញមុនពេលចាប់ផ្តើមអនុវត្តគម្រោងសាកល្បង។

## ២. ក្របខណ្ឌអង្គភាពថវិកា

### ២.១ និយមន័យនៃអង្គភាពថវិកា

អង្គភាពថវិកា គឺជាអង្គភាពស្ថិតក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័នដែលបង្កើតដោយរាជរដ្ឋាភិបាល។ អង្គភាពថវិកា គឺជាអង្គភាពដែលត្រូវបានទទួលអាណត្តិកិច្ចច្បាស់លាស់ក្នុងការអនុវត្តសកម្មភាពការងារ ដើម្បីបង្កើតបានជាលទ្ធផលជាក់លាក់ហើយដែលលទ្ធផលទាំងនោះត្រូវតែរួមចំណែកក្នុងការសម្រេចបាននូវគោលបំណងគោលនយោបាយអាទិភាពរបស់ក្រសួង ស្ថាប័ន។

អង្គភាពថវិកា សំដៅដល់អង្គភាពដែលមានសមត្ថភាពក្នុងការទទួលខុសត្រូវ និងមានភាពជាម្ចាស់ក្នុងការអនុវត្តសកម្មភាពការងារក្នុងការរៀបចំ និងការគ្រប់គ្រងថវិកា ព្រមទាំងក្នុងការត្រួតពិនិត្យលទ្ធផលនៃការអនុវត្តសកម្មភាពការងារ និងការអនុវត្តថវិកាដោយខ្លួនឯង ស្របតាមគោលការណ៍ និងនីតិវិធីរបស់ក្រសួង ស្ថាប័ន។ នៅកម្ពុជាបច្ចុប្បន្ន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង ស្ថាប័ននៅមានលក្ខណៈមជ្ឈការខ្ពស់នៅឡើយ (ភាគច្រើននៅត្រឹមកម្រិតទី១ គឺកម្រិតក្រសួង ស្ថាប័ន ដែលជាកម្រិតដឹកនាំ និងកំណត់គោលនយោបាយ)។ ប្រការនេះ ធ្វើឲ្យការបែងចែកមុខងារ ភារកិច្ច និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងក្រសួង ស្ថាប័ននៅមានភាពមិនច្បាស់លាស់ ទោះជាមានក្រសួង ស្ថាប័នមួយចំនួនដូចជា៖ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល បានវិភាជថវិកា និងផ្តល់សិទ្ធិក្នុងការអនុវត្តថវិកាដល់សាលារៀន និងមន្ទីរពេទ្យមួយចំនួនក៏ដោយ។ ដ្យាក្រាមខាងក្រោម បង្ហាញអំពីទំនាក់ទំនងរវាងរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន សិទ្ធិអំណាច និងការទទួលខុសត្រូវ ព្រមទាំងឧបករណ៍សម្រាប់គ្រប់គ្រងសមិទ្ធកម្មយ៉ាងច្បាស់លាស់នៅកម្រិតនីមួយៗ ដែលក្រសួង ស្ថាប័នអាចយកមកធ្វើជាមូលដ្ឋានក្នុងការកំណត់មុខងារ ភារកិច្ច ការទទួលខុសត្រូវ និងគណនេយ្យភាពនៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ខ្លួនបាន៖

## ដ្យាក្រាមទី១ រចនាសម្ព័ន្ធគ្រប់គ្រងក្រសួង ស្ថាប័ន



ជាលក្ខណៈអន្តរជាតិ ទោះបីប្រទេសនីមួយៗអាចមានរចនាសម្ព័ន្ធគ្រប់គ្រងខុសៗគ្នា ហើយមានកម្រិតវិមជ្ឈការ និងវិសហមជ្ឈការខុសគ្នាក៏ដោយក៏នៅក្នុងករណីភាគច្រើន ថវិកាប្រចាំឆ្នាំត្រូវបានអនុម័តដោយសភានៅកម្រិតទី១ ដែលជាកម្រិតដឹកនាំ និងកំណត់គោលនយោបាយឬកម្រិតដឹកនាំក្រសួង ស្ថាប័ន ប៉ុន្តែនៅក្នុងបណ្តាប្រទេសមួយចំនួនដូចជាៈ អាហ្វ្រិកខាងត្បូង និងហ្វីលីពីន ដែលមានប្រព័ន្ធថវិកាកម្មវិធីផ្តោតលើលទ្ធផល ថវិកាត្រូវបានអនុម័តដល់កម្រិតទី២ ដែលជាកម្រិតគ្រប់គ្រងបច្ចេកទេស និងកំណត់យុទ្ធសាស្ត្រ។ នៅក្នុងបណ្តាប្រទេសជាច្រើន ការវិភាជថវិកា ការអនុវត្ត និងការគ្រប់គ្រងថវិកា ត្រូវបានកំណត់ដល់កម្រិតទី៣ ដែលជាកម្រិតបច្ចេកទេស និងអនុវត្តសកម្មភាព។ ប៉ុន្តែសម្រាប់បណ្តាប្រទេសមួយចំនួនទៀត ការអនុវត្តជាក់ស្តែងនៃការទទួលខុសត្រូវទាំងនេះត្រូវបានកំណត់នៅត្រឹមកម្រិតខ្ពស់ជាង (កម្រិតទី១ និងទី២) ឬកម្រិតទាបជាងនេះ (កម្រិតទី៤ ឬកម្រិតទី៥)។ ការកំណត់ការអនុម័ត ការវិភាជ ការអនុវត្ត និងការគ្រប់គ្រងទៅតាមកម្រិតទាំងនេះ គឺផ្អែកលើរចនាសម្ព័ន្ធគ្រប់គ្រងក្រសួង ស្ថាប័ន និងក្របខណ្ឌច្បាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ប្រទេសនីមួយៗ។ គណនេយ្យភាពចំពោះការគ្រប់គ្រងថវិកា និងការគ្រប់គ្រងបុគ្គលិកភាគច្រើនត្រូវបានអនុវត្តនៅកម្រិតទី១។ ប៉ុន្តែនៅក្នុងប្រទេសមួយចំនួនដូចជាៈ ណូវែលហ្សេឡង់ និងអាហ្វ្រិកខាងត្បូងគណនេយ្យភាពនេះត្រូវបានធ្វើវិមជ្ឈការទៅកម្រិតទី២ និងទី៣។ គួរកត់សម្គាល់ថា ទោះជានៅកម្រិតណាក៏ដោយ គោលបំណងសំខាន់នៃការរៀបចំរចនាសម្ព័ន្ធនេះ គឺការបង្កើនប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ និងតម្លាភាពនៃរចនាសម្ព័ន្ធ និងប្រព័ន្ធថវិកា។ ផ្អែកតាមជម្រាបខាងលើ និងស្របតាមការអនុវត្តជាអន្តរជាតិ រាជរដ្ឋាភិបាលកម្ពុជា បានកំណត់អង្គភាពថវិកានៅកម្រិតទី៣ គឺកម្រិតនាយកដ្ឋានដែលដឹកនាំដោយកម្រិតទី១ គឺកម្រិតថ្នាក់ដឹកនាំ និងកំណត់គោលនយោបាយ និងគ្រប់គ្រងដោយកម្រិតទី២ គឺកម្រិតគ្រប់គ្រងបច្ចេកទេស និងកំណត់យុទ្ធសាស្ត្រ។ ដូច្នេះ គ្រប់អង្គភាពទាំងអស់ដែលបង្កើតឡើងដោយរាជរដ្ឋាភិបាលដែលមានអាណត្តិកិច្ចច្បាស់លាស់ ហើយស្ថិតនៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័ននៅកម្រិតទី៣ ដែលប្រើប្រាស់ថវិការបស់រដ្ឋ គឺសុទ្ធតែជាអង្គភាពដែលអាចរៀបចំឲ្យក្លាយទៅជាអង្គភាពថវិកាបាន។ អង្គភាពទាំងនោះមានដូចជាៈ នាយកដ្ឋាននៅក្នុងក្រសួង ស្ថាប័ន គ្រឹះស្ថានរដ្ឋបាលសាធារណៈ និងសហគ្រាសរបស់រដ្ឋ ដែលស្ថិតក្រោមឱវាទរបស់ក្រសួង ស្ថាប័ន។

## ២.២ អត្ថប្រយោជន៍នៃអង្គភាពថវិកា

ដូចដែលបានលើកឡើងខាងលើ ការអនុវត្តក្របខណ្ឌអង្គភាពថវិកា គឺជាមូលដ្ឋានដ៏សំខាន់មួយនៅក្នុងចំណោមមូលដ្ឋានសំខាន់ៗនានាសម្រាប់លើកកម្ពស់គណនេយ្យភាពហិរញ្ញវត្ថុ ដែលជាគោលដៅដ៏សំខាន់នៅក្នុងជំហានទី២ នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ជារួម ការបង្កើតក្របខណ្ឌអង្គភាពថវិកានឹងផ្តល់នូវអត្ថប្រយោជន៍ដូចខាងក្រោមៈ

១. អនុញ្ញាតឲ្យមានការបែងចែកមុខងារ និងការទទួលខុសត្រូវបានកាន់តែច្បាស់លាស់រវាងនាយកដ្ឋានហិរញ្ញវត្ថុ (អ្នកគ្រប់គ្រងថវិកា) និងនាយកដ្ឋានជំនាញ ឬអង្គភាពផ្គត់ផ្គង់សេវាសាធារណៈ (អ្នកប្រើប្រាស់ថវិកា)។

២. ជំរុញឲ្យមានការបង្កើនតម្លាភាព និងគណនេយ្យភាពក្នុងការអនុវត្តការងារ នៅក្នុងក្រសួង ស្ថាប័នកាន់តែប្រសើរឡើង ពិសេស តម្លាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ។

៣. អនុញ្ញាតឲ្យមានការរៀបចំរបាយការណ៍គណនេយ្យហិរញ្ញវត្ថុ និងរបាយការណ៍លទ្ធផលនៃការអនុវត្តថវិកាបានកាន់តែច្បាស់លាស់។

៤. អនុញ្ញាតឲ្យមានការរៀបចំ និងវិភាជថវិកាកាន់តែមានប្រសិទ្ធភាពជាងមុន ពិសេស ការគណនាតម្រូវការថវិកាកាន់តែសុក្រឹតជាងមុន និងការផ្សារភ្ជាប់ថវិកាទៅនឹងលទ្ធផលកាន់តែប្រសើរជាងមុន។

៥. បង្កលក្ខណៈងាយស្រួលដល់ការរៀបចំចំណាត់ថ្នាក់មុខងារ និងចំណាត់ថ្នាក់រដ្ឋបាល ការអនុវត្តថវិកាកម្មវិធី និងថវិកាសមិទ្ធកម្ម និងការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ។

៦. ជំរុញឲ្យមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងច្បាស់លាស់ ពិសេស ងាយស្រួលដល់ការរៀបចំយន្តការត្រួតពិនិត្យការអនុវត្តថវិកា លទ្ធផលនៃការអនុវត្តសកម្មភាពការងារ និងសមិទ្ធកម្មកាន់តែប្រសើរជាងមុន។

៧. ជំរុញឲ្យមានការទទួលខុសត្រូវ និងភាពជាម្ចាស់ក្នុងការអនុវត្តសកម្មភាពការងារដែលត្រូវបានប្រគល់ភារកិច្ចដោយក្រសួង ស្ថាប័ន។

៨. ជំរុញឲ្យមានការបង្កើនសមត្ថភាពជំនាញរបស់អង្គភាព និងបង្កើតរចនាសម្ព័ន្ធចាត់តាំង គ្រប់គ្រង និងត្រួតពិនិត្យលទ្ធផលការងារកាន់តែមានភាពច្បាស់លាស់។

៩. រួមចំណែកឲ្យក្រសួង ស្ថាប័នគ្រប់គ្រង និងអនុវត្តការងារបានកាន់តែប្រសើរ។

បន្ថែមលើអត្ថប្រយោជន៍ដែលបានរៀបរាប់ខាងលើ ការអនុវត្តក្របខណ្ឌអង្គភាពថវិកានេះ នឹងផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ចំពោះក្រសួង ស្ថាប័នដូចខាងក្រោម៖

- ការបែងចែងការទទួលខុសត្រូវ និងគណនេយ្យភាពកាន់តែច្បាស់លាស់ដល់មន្ត្រីចំពោះការអនុវត្តគ្រប់មុខងារ និងសកម្មភាពដែលក្រសួង ស្ថាប័នប្រគល់ជូន។
- ការធ្វើវិភាជចំណាយកាន់តែមានភាពជាក់ស្តែង ឆ្លើយតបទៅនឹងសកម្មភាពអាទិភាព និងកម្មវិធីចម្បងៗរបស់ក្រសួង ស្ថាប័ន។

- បង្កើនសមត្ថភាពក្នុងការធ្វើអំណះអំណាងនៃតម្រូវការថវិកា ពិសេស ការលើកកម្ពស់សមត្ថភាព ក្នុងការបញ្ជាក់ពីទំនាក់ទំនងរវាងការអនុវត្តគោលនយោបាយ និងការវិភាជថវិកាដែលបានស្នើសុំ។
- បង្កលក្ខណៈងាយស្រួល និងបង្កើនសមត្ថភាព និងប្រសិទ្ធភាពគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន។
- លើកកម្ពស់សមត្ថភាពរបស់ក្រសួង ស្ថាប័នក្នុងការបញ្ជាក់ជាសាធារណៈ អំពីមុខងារ សេវា និងសកម្មភាពដែលក្រសួងបានផ្តល់ព្រមទាំងចំណាយពាក់ព័ន្ធទាំងឡាយ។
- កាន់តែមានភាពទន់ភ្លន់ ក្នុងការកែសម្រួលថវិកាតាមការចាំបាច់ ដើម្បីសម្រេចគោលបំណងគោលនយោបាយ និងលទ្ធផលចុងក្រោយដែលបានកំណត់។

## ៣. នីតិវិធីក្នុងការរៀបចំអង្គភាពថវិកា

ដើម្បីបង្កលក្ខណៈងាយស្រួលដល់ក្រសួង ស្ថាប័នក្នុងការបង្កើតរចនាសម្ព័ន្ធអង្គភាពថវិកា នីតិវិធីជាជំហានៗត្រូវបានរៀបចំឡើង។ ខាងក្រោមនេះ គឺជាការណែនាំទៅលើជំហានទាំង៦ តាមលំដាប់លំដោយដែលចាប់ផ្តើមពីកម្រិតនៃការពិនិត្យលើបេសកកម្ម អាណត្តិកិច្ច និងគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន ហើយជាបន្តបន្ទាប់ រហូតដល់ការរៀបចំជាអង្គភាពថវិកាដើម្បីស្នើសុំការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### ៣.១ ជំហានទី១ ការពិនិត្យលើបេសកកម្ម អាណត្តិកិច្ច និងគោលបំណងគោលនយោបាយ

ជំហានទី១នៃការរៀបចំអង្គភាពថវិកា គឺការពិនិត្យលើគុណភាព និងវិសាលភាពនៃគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន។ មានគោលបំណងគោលនយោបាយប្រកបដោយគុណភាព គឺជាប្រការដ៏សំខាន់បំផុតនៅក្នុងការរៀបចំអង្គភាពថវិកា។ ថ្នាក់ដឹកនាំក្រសួងគួរពិនិត្យលើសកម្មភាពបច្ចុប្បន្នរបស់ក្រសួងដើម្បីបញ្ជាក់ថា តើវាមានសង្គតិភាពជាមួយនឹងអាណត្តិកិច្ច និងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងដែរឬទេ?។ ជាពិសេស ក្រសួងគួរពិនិត្យឡើងវិញលើច្បាប់អនុក្រឹត្យ និងបទបញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងការកំណត់បេសកកម្ម មុខងារ និងការទទួលខុសត្រូវទាំងមូលរបស់ខ្លួន។ ការពិនិត្យឡើងវិញនេះ គួរដឹកនាំដោយប្រធានស្ថាប័ន (កម្រិតទី១) ដែលជាកម្រិតដឹកនាំ និងកំណត់គោលនយោបាយ និងអគ្គលេខាធិការ ឬអគ្គនាយក ដែលជាកម្រិតគ្រប់គ្រងបច្ចេកទេស និងកំណត់យុទ្ធសាស្ត្រ (កម្រិតទី២)។ នៅក្នុងការពិនិត្យមើលឡើងវិញនេះ ក្រសួងគួរយោងទៅលើដ្យាក្រាម១ ស្តីពីរចនាសម្ព័ន្ធគ្រប់គ្រងក្រសួង ស្ថាប័ននៅក្នុងផ្នែក ២.២។ គោលដៅចំបងនៃជំហាននេះ គឺដើម្បីធានាថាគ្រប់គោលបំណងគោលនយោបាយ កម្មវិធី អនុកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព សុទ្ធតែត្រូវបានកំណត់យ៉ាងច្បាស់លាស់ និងដាក់លាក់នូវការទទួលខុសត្រូវ និង

គណនេយ្យភាពនៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន។ *ដូច្នេះជំហាននេះតម្រូវឲ្យក្រសួង ស្ថាប័នបំពេញតារាងទី១ ស្តីពីរចនាសម្ព័ន្ធគោលនយោបាយរបស់ក្រសួង ស្ថាប័ន*។ ក្នុងករណីដែលគោលបំណងគោលនយោបាយ មានសង្គតិភាពជាមួយអាណត្តិកិច្ច និងបេសកកម្មរបស់ក្រសួង ហើយកម្មវិធី អនុកម្មវិធីឬយុទ្ធសាស្ត្រអាទិភាព មានសង្គតិភាពជាមួយនឹងគោលបំណងគោលនយោបាយនោះ ក្រសួងពិតជាអាចភ្ជាប់មុខងារ និងភារកិច្ចរបស់អង្គភាពទាំងអស់របស់ខ្លួនទៅនឹងកម្មវិធី អនុកម្មវិធីឬយុទ្ធសាស្ត្រអាទិភាព និងគោលបំណងគោលនយោបាយទាំងមូលរបស់ក្រសួងបាន។ ផ្ទុយទៅវិញ ប្រសិនបើមុខងារ និងភារកិច្ចរបស់អង្គភាពមិនមានសង្គតិភាពទៅនឹងកម្មវិធី អនុកម្មវិធីឬយុទ្ធសាស្ត្រអាទិភាព និងគោលបំណងគោលនយោបាយទេនោះ ក្រសួងគួរធ្វើការពិនិត្យឡើងវិញ ដើម្បីកំណត់ពីមូលហេតុ និងស្វែងរកជម្រើសសម្រាប់ការកែលម្អក្នុងការបង្កើនសង្គតិភាពឡើងវិញ ដោយផ្អែកលើមូលដ្ឋាននៃទំនាក់ទំនងរវាងកម្រិតនីមួយៗ ដូចដែលមានបង្ហាញនៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន (ដ្យាក្រាមទី១) ហើយដែលនឹងត្រូវកំណត់នៅក្នុងជំហានទី២។

## ៣.២ ជំហានទី២ ការពិនិត្យលើរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័នបច្ចុប្បន្ន

គោលដៅសំខាន់នៃជំហានទី២ គឺការកំណត់ឲ្យបានច្បាស់លាស់នូវបន្ទាត់គណនេយ្យភាពរវាងកម្រិតនីមួយៗនៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង(អង្គការលេខ) ដូចមានបង្ហាញនៅក្នុងដ្យាក្រាមទី១។ ដូច្នេះ បន្ទាប់ពីការធ្វើឲ្យមានសង្គតិភាពរវាងបេសកកម្ម អាណត្តិកិច្ច គោលបំណងគោលនយោបាយ និងកម្មវិធី អនុកម្មវិធីឬយុទ្ធសាស្ត្រអាទិភាពរួចមក ក្រសួង ស្ថាប័នត្រូវពិនិត្យឡើងវិញលើការកំណត់មុខងារ ភារកិច្ច និងការទទួលខុសត្រូវរបស់កម្រិតនីមួយៗផ្អែកលើក្របខណ្ឌច្បាប់ដែលមានជាធរមាន ដើម្បីធានាថាកម្រិតនីមួយៗត្រូវបានកំណត់យ៉ាងច្បាស់លាស់ អំពីបន្ទាត់គណនេយ្យភាពរបស់ខ្លួន។ ដូច្នេះ*ជំហាននេះតម្រូវឲ្យក្រសួង ស្ថាប័ន បំពេញតារាងទី២ ស្តីពីរចនាសម្ព័ន្ធគ្រប់គ្រងក្រសួង ស្ថាប័ន និងតារាងទី៣ស្តីពីការផ្សារភ្ជាប់រចនាសម្ព័ន្ធគ្រប់គ្រងទៅនឹងរចនាសម្ព័ន្ធគោលនយោបាយរបស់ក្រសួង ស្ថាប័ន*។ វិសាលភាពនៃការពិនិត្យឡើងវិញនេះ គួរមានបញ្ចូលគ្រប់អង្គភាពទាំងអស់ដែលស្ថិតនៅក្រោមឱវាទរបស់ក្រសួង រួមមានសហគ្រាសសាធារណៈ និងស្ថាប័នរដ្ឋបាលសាធារណៈផងដែរ។

ពិតណាស់ថា រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័នបច្ចុប្បន្ន នៅមានកម្រិតខ្វះខាត ហើយការរៀបចំបន្ទាត់គណនយ្យភាពទៅតាមកម្រិតដូចបានកំណត់នៅក្នុងដ្យាក្រាមទី១ ក៏ពិតជានឹងត្រូវជួបប្រទះបញ្ហាប្រឈម។ ប៉ុន្តែក្នុងដំណាក់កាលសាកល្បងនេះ គួរផ្តោតជាសំខាន់ទៅលើកម្រិត៣ ដែលជាកម្រិតដែលត្រូវរៀបចំឲ្យទៅជាអង្គភាពថវិកា។ ក្នុងករណីដែលក្រសួងពិនិត្យឃើញថា មិនមានបន្ទាត់គណនេយ្យភាពច្បាស់លាស់ក្នុងរចនាសម្ព័ន្ធរបស់ខ្លួន ជាពិសេស នៅកម្រិតទី៣ដែលជាកម្រិតបច្ចេកទេស និងអនុវត្តសកម្មភាព នោះក្រសួងត្រូវតែកែសម្រួលឲ្យបានសមស្រប។ ជាក់ស្តែង ក្រសួងត្រូវពិនិត្យថា តើអង្គភាពនីមួយៗមានមុខងារ តួនាទី និងការទទួលខុសត្រូវច្បាស់លាស់ និងមានខ្សែសង្វាក់គ្រប់គ្រងជាក់លាក់ ព្រមទាំងមាន

ប្រព័ន្ធរបាយការណ៍ច្បាស់លាស់ឬទេ?។ ក្រសួងគួរផ្តល់ច្បាប់ចម្លងអង្គការលេខរបស់ខ្លួនភ្ជាប់ជាមួយរបាយការណ៍ស្តីពីគម្រោងសាកល្បងអង្គភាពថវិកាមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីវាយតម្លៃ។

## ៣.៣ ជំហានទី៣ ការពិនិត្យ និងវាយតម្លៃលើអង្គភាពដែលអាចក្លាយជាអង្គភាពថវិកា

គោលដៅចម្បងនៅក្នុងជំហានទី៣នេះ គឺការវាយតម្លៃទៅលើអង្គភាពកម្រិត៣ ដែលបានពិនិត្យនៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ននៅជំហានទី២ ដើម្បីធានាថាតើអង្គភាពទាំងនោះអាចក្លាយជាអង្គភាពថវិកាបានឬទេ? ដោយផ្អែកលើលក្ខខណ្ឌវិនិច្ឆ័យទាំង៧ដូចខាងក្រោម៖

១. ជាអង្គភាពដែលត្រូវបានបង្កើតដោយផ្អែកលើគោលបំណងគោលនយោបាយរបស់ក្រសួង ហើយស្ថិតក្នុងកម្រិតទី៣នៃរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន និងត្រូវបានកំណត់មុខងារ និងភារកិច្ច ព្រមទាំងបន្ទាត់គណនេយ្យភាពច្បាស់លាស់

២. ជាអង្គភាពដែលមានសមិទ្ធកម្ម ឬលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយ នៅក្នុងកម្រិតដែលអាចវាស់វែងបាន

៣. ជាអង្គភាពដែលមានទំហំសមស្រប (ទំហំការងារ ទំហំតម្រូវការបុគ្គលិក និងទំហំតម្រូវការថវិកា) និងប្រកបដោយនិរន្តភាព

៤. ជាអង្គភាពដែលមានភាពជាម្ចាស់ និងការទទួលខុសត្រូវក្នុងការដឹកនាំ និងគ្រប់គ្រងប្រកបដោយគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ

៥. ជាអង្គភាពដែលមានសមត្ថភាពក្នុងការរៀបចំផែនការសកម្មភាពការងារ ផែនការយុទ្ធសាស្ត្រ និងថវិកាប្រចាំឆ្នាំ និងគ្រប់គ្រងការអនុវត្តផែនការសកម្មភាពការងារ និងគ្រប់គ្រងការអនុវត្តថវិកាប្រកបដោយប្រសិទ្ធភាព

៦. ជាអង្គភាពរដ្ឋដែលទទួលបានថវិកាតាមរយៈប្រព័ន្ធថវិការដ្ឋ

៧. ជាអង្គភាពដែលទទួលបានឬគួរវិភាជថវិកាប្រចាំឆ្នាំ និងអាចទទួលខុសត្រូវលើការអនុវត្ត និងតាមដានថវិកាបាន។

ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង (ប្រព័ន្ធគ្រប់គ្រងស្ថាប័ន) និងរចនាសម្ព័ន្ធគោលនយោបាយ (ប្រព័ន្ធត្រួតពិនិត្យសមិទ្ធកម្ម) ដែលមានសង្គតិភាពនឹងគ្នានៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័នគឺជាកត្តាគន្លឹះដើម្បីទទួលបានអត្ថប្រយោជន៍ពីការដាក់ឲ្យអនុវត្តអង្គភាពថវិកា។ ***ក្រោយពីក្រសួង ស្ថាប័ន បានវាយតម្លៃទៅលើអង្គភាពកម្រិតទី៣ទាំងអស់នៅក្នុងអង្គការលេខរបស់ខ្លួន ដោយផ្អែកលើលក្ខខណ្ឌវិនិច្ឆ័យទាំង៧ខាងលើរួចមក ក្រសួង ស្ថាប័នត្រូវបញ្ចូលអង្គភាពទាំងនោះទៅក្នុងតារាងទី៤*** (លទ្ធផលនៃការវាយតម្លៃលើអង្គភាពកម្រិតទី៣ នៃឧបសម្ព័ន្ធ១) ដោយត្រូវបញ្ជាក់អំពីភាពសមស្រប ឬមិនទាន់សមស្របនៃអង្គភាពនីមួយៗ ទៅនឹងលក្ខខណ្ឌវិនិច្ឆ័យទាំង៧ និងបញ្ជាក់អំពីតម្រូវការសម្រាប់កែលម្អ ព្រមទាំងស្នើឡើងនូវ

សកម្មភាពសម្រាប់កែលម្អ ចំពោះអង្គភាពដែលមិនទាន់មានលក្ខណៈសមស្របទាំងស្រុង។ តារាងនេះនឹងជួយដល់ក្រសួងនៅក្នុងការកំណត់ថា តើអង្គភាពកម្រិតទី៣ទាំងនោះអាចបំពេញតាមលក្ខខណ្ឌវិនិច្ឆ័យខាងលើបានកម្រិតណាក្នុងការរៀបចំឲ្យទៅជាអង្គភាពថវិកា។ ទន្ទឹមនឹងនេះ តារាងទី៤នឹង ជួយដល់ក្រសួងផងដែរក្នុងការស្វែងរកចំណុចដែលត្រូវកែលម្អ ទៅលើអង្គភាពដែលមិនទាន់បំពេញបានតាមលក្ខខណ្ឌវិនិច្ឆ័យទាំងស្រុងដើម្បីឈានទៅរៀបចំផែនការសកម្មភាពសម្រាប់កែលម្អ។ គោលបំណងនៃជំហានទី៣នេះ គឺដើម្បីឲ្យក្រសួងអាចកំណត់បានថា តើអង្គភាពណាខ្លះដែលបំពេញលក្ខខណ្ឌវិនិច្ឆ័យបានទាំងស្រុង ហើយអង្គភាពណាខ្លះមិនទាន់អាចបំពេញបានទាំងស្រុង។ ទោះជាក្រសួង អាចលើកសំណើដើម្បីកែលម្អអង្គភាពមួយចំនួនដែលមិនទាន់អាចបំពេញបានតាមលក្ខខណ្ឌវិនិច្ឆ័យទាំងស្រុង ដើម្បីប្រែក្លាយឲ្យទៅជាអង្គភាពថវិកាក៏ដោយ ប៉ុន្តែ ប្រសិនបើអង្គភាពកម្រិត៣ទាំងនោះមិនមានមុខងារ ភារកិច្ច និងសមិទ្ធកម្មច្បាស់លាស់ ឬមុខងារ ភារកិច្ច និងសមិទ្ធកម្មទាំងនោះមិនស្របទៅនឹងឬមិនបម្រើឲ្យគោលបំណងគោលនយោបាយរបស់ក្រសួងទេនោះ អង្គភាពទាំងនោះនឹងមិនអាចក្លាយទៅជាអង្គភាពថវិកាបានទេ។ នៅក្នុងដំណាក់កាលសាកល្បងចំពោះអង្គភាពដែលមិនទាន់បំពេញតាមលក្ខខណ្ឌវិនិច្ឆ័យទាំងស្រុង ក្រសួងត្រូវអនុវត្តទៅតាមយុទ្ធសាស្ត្រនៃការដាក់ឲ្យអនុវត្តអង្គភាពថវិកាជាជំហានៗ ដូចមានបញ្ជាក់នៅក្នុងផ្នែកទី៤នៃគោលការណ៍ណែនាំនេះ។ តារាងនេះ គួរត្រូវបានបំពេញដោយក្រុមការងាររៀបចំថវិការបស់ក្រសួង ពិសេស ត្រូវមានការចូលរួមពីនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និងនាយកដ្ឋានជំនាញ ហើយគួរត្រូវបានត្រួតពិនិត្យ និងឯកភាពដោយអគ្គលេខាធិការឬអគ្គនាយកដែលទទួលបន្ទុកគ្រប់គ្រងរួមលើអង្គភាពទាំងនោះ ព្រមទាំងអនុម័តដោយប្រធានស្ថាប័ន មុននឹងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### ៣.៤ ជំហានទី៤ ការរៀបចំបង្កើតអង្គភាពថវិកា

គោលដៅចម្បងនៅក្នុងជំហានទី៤នេះ គឺដើម្បីឲ្យក្រសួង ស្ថាប័នអាចវាយតម្លៃទៅលើអង្គភាពដែលមិនទាន់សមស្របទៅនឹងលក្ខខណ្ឌវិនិច្ឆ័យទាំង៧ និងការរៀបចំផែនការសកម្មភាពការងារសម្រាប់កែលម្អអង្គភាពទាំងនោះ ហើយឈានទៅកំណត់យកអង្គភាពមួយចំនួនដែលបំពេញតាមលក្ខខណ្ឌវិនិច្ឆ័យបានច្រើនជាងគេដាក់ស្នើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងឯកភាព។ ***ដូច្នេះ ជំហាននេះតម្រូវឲ្យក្រសួង ស្ថាប័នបំពេញតារាងទី៥ ស្តីពីការរៀបចំផែនការសកម្មភាពសម្រាប់កែលម្អដែលមាននៅក្នុងឧបសម្ព័ន្ធ១ ដោយផ្អែកលើលទ្ធផលនៅក្នុងតារាងទី១ ដល់ទី៤ ពិសេស ដើម្បីធានាសង្គតិភាពរវាងរចនាសម្ព័ន្ធគោលនយោបាយ និងរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន***។ គួរកត់សម្គាល់ថា អង្គភាពថវិកាដែលក្រសួង ស្ថាប័នកំពុងរៀបចំនេះ គឺស្ថិតក្នុងកម្រិតទី៣នៃរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន (ដ្យាក្រាម១ រចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ននៅក្នុងផ្នែក២.២) ដែលត្រូវតែមានការកំណត់ច្បាស់លាស់នូវមុខងារ ភារកិច្ច និងការទទួលខុសត្រូវលើការអនុវត្តផែនការសកម្មភាពដែលពាក់ព័ន្ធទៅនឹងអនុកម្មវិធី កម្មវិធីឬ/និងយុទ្ធសាស្ត្រអាទិភាពដែលចាំបាច់ក្នុងការសម្រេចបាននូវគោលបំណងគោលនយោបាយ ដូចមានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ន។ ទោះបីដំណាក់កាលដំបូងនៃការអនុវត្តសាកល្បងនឹងផ្តោតទៅលើការបង្កើតរចនាសម្ព័ន្ធអង្គភាពថវិការបស់ក្រសួង ស្ថាប័នក៏ដោយ ក៏បញ្ហាសំខាន់ចំពោះមុខ គឺការបែងចែកមុខងារ ភារកិច្ច និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងថវិការបស់ក្រសួង ស្ថាប័ន ពិសេស រវាងនាយកដ្ឋានហិរញ្ញវត្ថុ (អ្នកចាត់ចែងគ្រប់គ្រងថវិកា)

និងនាយកដ្ឋានជំនាញ (អ្នកប្រើប្រាស់ និងអនុវត្តថវិកា) ដែលជាគន្លឹះក្នុងការពង្រឹង និងលើកកម្ពស់ការទទួលខុសត្រូវ និងគណនេយ្យភាពចំពោះលទ្ធផល និងសមិទ្ធកម្ម។ អនុសាសន៍សម្រាប់កែលម្អ និងពង្រឹងការទទួលខុសត្រូវឲ្យបានច្បាស់លាស់រវាងនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និងនាយកដ្ឋានជំនាញ មានបង្ហាញនៅក្នុងឧបសម្ព័ន្ធ២ នៃគោលការណ៍ណែនាំនេះ។

## ៣.៥ ជំហានទី៥ ការរៀបចំ និងអនុម័តលើរបាយការណ៍ស្តីពីការរៀបចំអង្គភាពថវិកា

គោលដៅចម្បងនៅក្នុងជំហានទី៥នេះ គឺដើម្បីឲ្យក្រសួង ស្ថាប័នបូកសរុបលទ្ធផលពីជំហានទី១ ដល់ទី៤ដើម្បីឈានទៅកំណត់អ្នកទទួលខុសត្រូវ និងពេលវេលាសម្រាប់ការអនុវត្តសកម្មភាពដែលត្រូវកែលម្អ និងកំណត់អង្គភាពដែលក្រសួង ស្ថាប័នយល់ថាអាចក្លាយជាអង្គភាពថវិកានៅឆ្នាំ២០១៥ ព្រមទាំងកំណត់នូវបណ្តាបញ្ហាប្រឈមដែលក្រសួង ស្ថាប័នយល់ថាអាចនឹងកើតមានឡើងក្នុងពេលដាក់ឲ្យអនុវត្តសាកល្បងនៅឆ្នាំ២០១៥។ ដូច្នេះ ***នៅក្នុងជំហាននេះ ក្រសួង ស្ថាប័នត្រូវបំពេញតារាងទី៦នៃឧបសម្ព័ន្ធ១ ស្តីពីរបាយការណ៍ស្តីពីការស្នើសុំអង្គភាពថវិការបស់ក្រសួង ស្ថាប័ន***។ ពិតណាស់ថា ក្រសួង ស្ថាប័នមួយចំនួនអាចនឹងរកឃើញថា អង្គភាពកម្រិត៣មួយចំនួនរបស់ខ្លួនដែលត្រូវរៀបចំឲ្យក្លាយទៅជាអង្គភាពថវិកា មិនទាន់បំពេញបានតាមលក្ខខណ្ឌវិនិច្ឆ័យទាំងស្រុងនោះទេ ប៉ុន្តែ ក្រសួង ស្ថាប័នក៏មិនត្រូវរារែកក្នុងការស្នើសុំធ្វើឲ្យអង្គភាពកម្រិត៣ទាំងនោះ ក្លាយទៅជាអង្គភាពថវិកានៅក្នុងឆ្នាំ២០១៥នោះទេ ពិសេស ប្រសិនបើក្រសួង ស្ថាប័នបានរកឃើញច្បាស់អំពីមូលហេតុ ព្រមទាំងបានរៀបចំផែនការសកម្មភាពសម្រាប់ការកែលម្អទៅតាមលក្ខណៈសម្បត្តិនីមួយៗដូចមានបង្ហាញនៅក្នុងតារាងទី៥ និងទី៦ នៃឧបសម្ព័ន្ធ១។ អាស្រ័យដោយយល់ឃើញបែបនេះហើយ ទើបការដាក់ឲ្យអនុវត្តសាកល្បងអង្គភាពថវិកានៅដំណាក់កាលទី១នេះ ត្រូវបានចាប់ផ្តើមជាមួយក្រសួងថវិកាកម្មវិធីទាំង៨ ដោយក្រសួងទាំងនេះ មានរចនាសម្ព័ន្ធគោលនយោបាយ និងកម្មវិធី ហើយអាចផ្សារភ្ជាប់ទៅនឹងរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័នបានងាយស្រួលជាងក្រសួង ស្ថាប័នដទៃ។

## ៣.៦ ជំហានទី៦ ការត្រួតពិនិត្យ និងឯកភាពលើសំណើបង្កើតអង្គភាពថវិកា

ជំហានទី៦ គឺការត្រួតពិនិត្យ និងឯកភាពលើសំណើបង្កើតអង្គភាពថវិការបស់ក្រសួង ស្ថាប័ន ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដូច្នេះ បន្ទាប់ពីទទួលបានរបាយការណ៍ស្តីពីការរៀបចំ និងសំណើបង្កើតអង្គភាពថវិការបស់ក្រសួង ស្ថាប័ន នាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងធ្វើការវាយតម្លៃបូកសរុប និងរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យលើសំណើសុំបង្កើតអង្គភាពថវិការបស់ក្រសួង ស្ថាប័ន ដើម្បីដាក់សុំការអនុម័តពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បន្ទាប់មក នឹងត្រូវរៀបចំប្រកាសអន្តរក្រសួង រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ននីមួយៗ ដើម្បីដាក់ឲ្យអនុវត្តអង្គភាពថវិកាដែលបានអនុម័ត។

## ៤. ការដាក់ឲ្យអនុវត្តអង្គភាពថវិកា

ដូចបានគូសបញ្ជាក់ខាងលើថា ការដាក់ឲ្យអនុវត្តអង្គភាពថវិកា មិនមែនគ្រាន់តែជាមូលដ្ឋានសម្រាប់ការបង្កើតគណនេយ្យភាពហិរញ្ញវត្ថុនៃគោលដៅដំណាក់កាលទី២ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប៉ុណ្ណោះទេ តែអង្គភាពថវិកាថែមទាំងជាមូលដ្ឋានដ៏សំខាន់សម្រាប់គោលដៅដំណាក់កាលទី៣ និងទី៤ ផងដែរនោះគឺ ការធានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងគណនេយ្យភាពចំពោះសមិទ្ធកម្ម។

ជារួម ការដាក់ឲ្យអនុវត្តអង្គភាពថវិកា នឹងត្រូវធ្វើឡើងជា៣ ដំណាក់កាលគឺ (១)ដំណាក់កាលសាកល្បង យ៉ាងហោចជាមួយក្រសួងសាកល្បងថវិកាកម្មវិធី (២)ដំណាក់កាលពង្រឹង និងពង្រីក ដែលត្រូវផ្អែកលើបទពិសោធន៍នៃការសាកល្បង និង(៣)ការឈានទៅអនុវត្តអង្គភាពថវិកាពេញលេញ និងគ្រប់ក្រសួងស្ថាប័ន។ ខាងក្រោមគឺជាយុទ្ធសាស្ត្រ និងផែនការសកម្មភាពលម្អិត និងជាក់ស្តែងសម្រាប់ការដាក់ឲ្យអនុវត្តអង្គភាពថវិកាជាជំហានៗ និងជាដំណាក់កាលៗ ស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

### ៤.១ យុទ្ធសាស្ត្រនៃការដាក់ឲ្យអនុវត្តអង្គភាពថវិកា

**១. ដាក់ឲ្យអនុវត្តសាកល្បងអង្គភាពថវិកាយ៉ាងហោចណាស់នៅក្រសួងសាកល្បងថវិកាកម្មវិធីទាំង៨ នៅឆ្នាំ២០១៥។** ការដាក់ឲ្យអនុវត្តអង្គភាពថវិកានេះ នឹងជួយបង្កើនភាពច្បាស់លាស់ក្នុងការបែងចែកមុខងារ និងការទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពការងារនៅកម្រិតចង្កោមសកម្មភាព និងអនុកម្មវិធី ព្រមទាំងជួយដល់ការពង្រឹងគណនេយ្យភាព និងការធ្វើរបាយការណ៍លទ្ធផលនៅកម្រិតនាយកដ្ឋាន ឬអង្គភាពជំនាញដែលជា អ្នកអនុវត្តសកម្មភាព និងបង្កើតលទ្ធផលដោយផ្ទាល់។ ជាពិសេស ការដាក់ឲ្យអនុវត្តអង្គភាពថវិកានេះ នឹងជំរុញឲ្យមានការចូលរួមពីនាយកដ្ឋាន ឬអង្គភាពជំនាញប្រកបដោយការទទួលខុត្រូវក្នុងការរៀបចំថវិកា នឹងជំរុញឲ្យមានការពង្រឹងសមត្ថភាពវិភាជ និងគ្រប់គ្រងថវិកាប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពរបស់នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្នុងការដើរតួនាទីជាអ្នកបូកសរុប និងសម្របសម្រួលជាមួយគ្រប់នាយកដ្ឋានជំនាញ ព្រមទាំងក្នុងតួនាទីជាសេនាធិការរបស់ក្រុមការងាររៀបចំថវិការបស់ក្រសួងស្ថាប័ន និងប្រធានស្ថាប័នក្នុងការគ្រប់គ្រងថវិការបស់ក្រសួង។

**២. វាយតម្លៃការសាកល្បងអង្គភាពថវិកា និងការរៀបចំយុទ្ធសាស្ត្រពង្រឹង និងពង្រីកនៃឆ្នាំ២០១៦ ឬ ២០១៧។** មានន័យថា បន្ទាប់ពីការដាក់ឲ្យអនុវត្តសាកល្បងនៅឆ្នាំ២០១៥ រួចមក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងត្រូវពិនិត្យ វាយតម្លៃ ដើម្បីស្វែងរកចំណុចខ្លាំង និងចំណុចខ្សោយ ព្រមទាំងបញ្ហាប្រឈម ហើយរៀបចំយុទ្ធសាស្ត្រពង្រឹង និងពង្រីកការអនុវត្តអង្គភាពថវិកានេះ។ ការពង្រឹង និងពង្រីកនេះ នឹងត្រូវស្របគ្នាទៅនឹងការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធីនៅក្រសួង ស្ថាប័នដែលស្ម័គ្រចិត្តដ៏ទៃទៀត។

**៣. ឈានទៅអនុវត្តអង្គភាពថវិកាពេញលេញនៅឆ្នាំ២០១៨ ឬ២០២០** ស្របគ្នាទៅនឹងការឈានទៅអនុវត្តអង្គភាពថវិកាកម្មវិធីពេញលេញ ដែលតម្រូវឲ្យការផ្លាស់ប្តូរប្រព័ន្ធថវិកាទាំងស្រុង ពីប្រព័ន្ធដែលផ្អែកលើ

ជាតុចូល (ថវិកាតាមកម្មវិធី) នោះ នឹងទាមទារឲ្យគ្រប់ក្រសួង ស្ថាប័នទាំងអស់អនុវត្តអង្គភាពថវិកាយ៉ាងពេញលេញ។

## ៤.២ ផែនការសកម្មភាពដើម្បីដាក់ឲ្យអនុវត្តអង្គភាពថវិកា

| **យុទ្ធសាស្ត្រ** | **ផែនការសកម្មភាព** | | |
|---|---|---|---|
| | **ឆ្នាំ២០១៣** | **ឆ្នាំ២០១៤** | **ឆ្នាំ២០១៥** |
| **១-ដាក់ឲ្យអនុវត្តសាកល្បងអង្គភាពថវិកាយ៉ាងហោចណាស់នៅក្រសួងសាកល្បងថវិកាកម្មវិធីទាំង៨ នៅឆ្នាំ ២០១៥** | - បញ្ចប់ការរៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំអង្គភាពថវិកា<br>- អនុម័តគោលការណ៍ណែនាំ និងចេញអនុក្រឹត្យអនុវត្ត<br>- អនុម័តលើអង្គភាពថវិការបស់ក្រសួងទាំង៨<br>- តម្រូវឲ្យគ្រប់ក្រសួងរិកាដថវិកាដល់នាយកដ្ឋាន (ថវិកាឆ្នាំ២០១៤) | - ក្រសួងសាកល្បងទាំង ៨ ត្រូវរៀបចំថវិកាឆ្នាំ ២០១៥ ដោយប្រើអង្គភាពថវិកាដែលបានអនុម័ត | |
| **២-វាយតម្លៃការសាកល្បងអង្គភាពថវិកា និងការរៀបចំយុទ្ធសាស្ត្រពង្រឹង និងពង្រីកនៃឆ្នាំ ២០១៦ ឬ២០១៧** | | | - ត្រួតពិនិត្យឡើងវិញលើគោលការណ៍នៃនាំស្តីពីការរៀបំអង្គភាពថវិកា និងយុទ្ធសាស្ត្រដាក់ឲ្យអនុវត្ត<br>- អនុញ្ញាតឲ្យក្រសួងដែលស្ម័គ្រចិត្តចូលរួមអនុវត្តអង្គភាពថវិកាសម្រាប់ការរៀបចំថវិកាឆ្នាំ២០១៦ |

| **យុទ្ធសាស្ត្រ** | **ផែនការសកម្មភាព** | | |
|---|---|---|---|
| | **ឆ្នាំ២០១៣** | **ឆ្នាំ២០១៤** | **ឆ្នាំ២០១៥** |
| ៣-ឈានទៅអនុវត្តអង្គភាពថវិកាពេញលេញនៅឆ្នាំ២០១៨ ឬ២០២០ | | | |

# ឧបសម្ព័ន១ តារាងសម្រាប់ក្រសួង ស្ថាប័នបំពេញតាមជំហាននីមួយៗ

## តារាងទី១ រចនាសម្ព័ន្ធគោលនយោបាយរបស់ក្រសួង ស្ថាប័ន

## (ជំហានទី១)

**ក្រសួង ______________________________**

គោលបំណងនៃការរៀបចំតារាងនេះ គឺដើម្បីបង្ហាញអំពីរចនាសម្ព័ន្ធគោលនយោបាយរបស់ក្រសួង ស្ថាប័ន ក្នុងគោលដៅធានាសង្គតិភាពគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ននៅក្នុងផែនការយុទ្ធ សាស្រ្តថវិកា ទៅនឹងគោលនយោបាយថ្នាក់ជាតិ( ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ)។

| គោលបំណងគោលនយោបាយ | កម្មវិធី/យុទ្ធសាស្រ្តអាទិភាព | អនុកម្មវិធី |
|---|---|---|
| ១. | ១.១ | ១.១.១ |
| | | ១.១.២ |
| | | ១.១.៣ |
| | | ... |
| | ១.២ | ១.២.១ |
| | | ១.២.២ |
| | | ១.២.៣ |
| | ... | ... |
| ២. | ២.១ | ២.១.១ |
| | | ២.១.២ |
| | | ២.១.៣ |
| | | .... |
| | ២.២ | ២.២.១ |
| | | ២.២.២ |
| | | ២.២.៣ |
| | | ..... |

# តារាងទី២ រចនាសម្ព័ន្ធគ្រប់គ្រងក្រសួង ស្ថាប័ន

## (ជំហានទី២)

**ក្រសួង:________________________________**

គោលបំណងនៃការរៀបចំតារាងនេះ គឺដើម្បីបង្ហាញអំពីរចនាសម្ព័ន្ធគ្រប់គ្រងដែលបញ្ជាក់អំពីបន្ទាត់គណនេយ្យភាពរវាងកម្រិតនីមួយៗរបស់ក្រសួង ស្ថាប័ននាពេលបច្ចុប្បន្ន។ ពិតណាស់ថា ក្រសួងស្ថាប័នមួយចំនួនអាចមានរចនាសម្ព័ន្ធគ្រប់គ្រងបច្ចុប្បន្នមិនស្របគ្នាទៅនឹងរចនាសម្ព័ន្ធដែលត្រូវរៀបចំនេះ ( ដូចបានគូសបញ្ជាក់ និងណែនាំនៅក្នុងចំនុច៣.២ នៃឯកសារនេះ )។ ក្នុងករណីនេះ សូមភ្ជាប់មកជាមួយនូវតារាងអង្គការលេខបច្ចុប្បន្នរបស់ក្រសួង ជាមួយនឹងតារាងទី២នេះ។

| កម្រិតដឹកនាំ និងកំណត់គោលនយោបាយ (កម្រិតទី១) | អគ្គលេខាធិការ-អគ្គនាយក (កម្រិតទី២) | នាយកដ្ឋាន-ឋានៈស្មើ (កម្រិតទី៣) | អង្គភាពក្រោមឱវាទ (កម្រិតទី៤) |
|---|---|---|---|
| | ១. | ១.១ | ១.១.១ |
| | | | ១.១.២ |
| | | | ១.១.៣ |
| | | ១.២ | ១.២.១ |
| | | | ១.២.២ |
| | | | ១.២.៣ |
| | ២. | ២.១ | ២.១.១ |
| | | | ២.១.២ |
| | | | ២.១.៣ |
| | | ២.២ | ២.២.១ |
| | | | ២.២.២ |
| | | | ២.២.៣ |

## តារាងទី៣ ការផ្សារភ្ជាប់រចនាសម្ព័ន្ធគ្រប់គ្រងទៅនឹងរចនាសម្ព័ន្ធគោលនយោបាយ របស់ក្រសួង ស្ថាប័ន

(ជំហានទី២)

គោលបំណងនៃការរៀបចំតារាងនេះ គឺដើម្បីបង្ហាញអំពីទំនាក់ទំនងរវាងរចនាសម្ព័ន្ធគ្រប់គ្រង និងរចនាសម្ព័ន្ធគោលនយោបាយរបស់ក្រសួង ស្ថាប័ន (ទំនាក់ទំនងអំពីសិទ្ធិអំណាច និងការទទួលខុសត្រូវ) ដែលក្រសួង ស្ថាប័នត្រូវកំណត់មុខងារ ភារកិច្ច ការទទួលខុសត្រូវ និងគណនេយ្យភាពឲ្យបានច្បាស់លាស់ទៅតាមកម្រិតនីមួយៗ និងទៅតាមរចនាសម្ព័ន្ធគោលនយោបាយប្រកបដោយសង្គតិភាព(គោលបំណងគោលនយោបាយកម្មវិធី/យុទ្ធសាស្ត្រអាទិភាពនិងអនុកម្មវិធី)។ពិតណាស់ថា ក្រសួង ស្ថាប័នមួយចំនួនអាចមានរចនាសម្ព័ន្ធគ្រប់គ្រងបច្ចុប្បន្នមិនស្របគ្នាទៅ នឹងរចនាសម្ព័ន្ធគោលនយោបាយឬអាចមិនមានរចនាសម្ព័ន្ធគោលនយោបាយច្បាស់លាស់ ដូចមានបង្ហាញក្នុងតារាងខាងក្រោមនេះ។ ប្រការនេះអាចធ្វើឲ្យក្រសួង ស្ថាប័នមានការលំបាកក្នុងការបន្សីគ្នារវាងរចនាសម្ព័ន្ធគ្រប់គ្រង និងរចនាសម្ព័ន្ធគោលនយោបាយ។ សូមភ្ជាប់មកជាមួយនូវតារាងបញ្ជាក់អំពីរចនាសម្ព័ន្ធគោលនយោបាយ ឬក្របខណ្ឌការងារបច្ចុប្បន្នរបស់ក្រសួង ជាមួយនឹងតារាងទី៣នេះ។

**ក្រសួង:** ________________________________

| រចនាសម្ព័ន្ធគោលនយោបាយ | អគ្គនាយក | នាយកដ្ឋាន |
|---|---|---|
| ១. គោលបំណងគោលនយោបាយ | | |
| ១.១ កម្មវិធី/យុទ្ធសាស្ត្រអាទិភាព | | |
| ១.១.១ អនុកម្មវិធី/យុទ្ធសាស្ត្រអាទិភាព | | |
| ១.២ កម្មវិធី/យុទ្ធសាស្ត្រអាទិភាព | | |
| ១.២.១ អនុកម្មវិធី/យុទ្ធសាស្ត្រអាទិភាព | | |
| ១.២.២ អនុកម្មវិធី/យុទ្ធសាស្ត្រអាទិភាព | | |
| ២. គោលបំណងគោលនយោបាយ | | |
| ២.១ កម្មវិធី/យុទ្ធសាស្ត្រអាទិភាព | | |
| ២.១.១ អនុកម្មវិធី/យុទ្ធសាស្ត្រអាទិភាព | | |
| ២.១.២ អនុកម្មវិធី/យុទ្ធសាស្ត្រអាទិភាព | | |
| ២.២ កម្មវិធី/យុទ្ធសាស្ត្រអាទិភាព | | |

| រចនាសម្ព័ន្ធគោលនយោបាយ | អគ្គនាយក | នាយកដ្ឋាន |
|---|---|---|
| ២.២.១ អនុកម្មវិធី/យុទ្ធសាស្ត្រអាទិភាព | | |
| ២.២.២ អនុកម្មវិធី/យុទ្ធសាស្ត្រអាទិភាព | | |

## តារាងទី៤ ការវាយតម្លៃតាមលក្ខខណ្ឌវិនិច្ឆ័យអង្គភាពថវិកា
## (ជំហានទី៣)

នៅក្នុងជំហានទី១ និងជំហានទី២ ក្រសួងនឹងមានអង្គភាព ដែលបានកំណត់ចេញនៅក្នុងរចនាសម្ព័ន្ធស្ថាប័នរបស់ខ្លួនរួចស្រេច ដែលត្រូវបានគាំទ្រដោយថវិការបស់ក្រសួង នៅក្នុងលក្ខខណ្ឌវិនិច្ឆ័យទី១ ទី២ និងទី៣ ខាងក្រោម។ ក្រសួងក៏នឹងបានកំណត់ផងដែរថាតើអង្គភាពរបស់ស្ថាប័នមានឬក៏មិនមានការទទួលខុសត្រូវ និង គណនេយ្យភាពច្បាស់លាស់ចំពោះការសម្រេចបាននូវលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយរបស់កម្មវិធី និង យុទ្ធសាស្ត្រ ដូចមាននៅក្នុងលក្ខខណ្ឌវិនិច្ឆ័យទី៣ ខាងក្រោមនេះ។ គោលបំណងរបស់តារាងនេះ គឺដើម្បីវាយតម្លៃថាតើនៅកម្រិតទី៣ របស់ស្ថាប័ន នាពេលបច្ចុប្បន្ន មានឬក៏មិនមានអាណត្តិកិច្ចច្បាស់លាស់ ដែលមានសង្គតិភាពជាមួយនឹងបេសកកម្មរបស់ក្រសួងមានទំហំ និងធនធានសមស្រប និងមានសមត្ថភាពក្នុងការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពការងារ និងថវិកាប្រចាំឆ្នាំ មានភាពជាម្ចាស់ និងការទទួលខុសត្រូវចំពោះការដឹកនាំ និងការគ្រប់គ្រង មានសមត្ថភាពចំពោះការទទួលខុសត្រូវក្នុងការគ្រប់គ្រងការងារឲ្យមានប្រសិទ្ធភាពដែរឬទេ។

ខាងក្រោមនេះ ជាលក្ខខណ្ឌវិនិច្ឆ័យ ដែលបានកំណត់ដោយស្ថាប័នសម្រាប់បំពេញតាមលក្ខខណ្ឌវិនិច្ឆ័យ។ ចំពោះលក្ខខណ្ឌវិនិច្ឆ័យនីមួយៗ ដែលជាការទទួលខុសត្រូវរបស់អង្គភាពថវិកា (លេខ៥, ៦ , ៧ និង៨) បង្ហាញថាតើអង្គភាពពិតជាស្របតាម ឬមិនស្របតាមតម្រូវការហើយគួរធ្វើការកែលម្អទាំងស្រុងដែរឬទេ។ នៅពេលដែលមានតម្រូវការឲ្យធ្វើការកែលម្អសកម្មភាពដែលបានស្នើសុំនឹងត្រូវបានយកមកដោះស្រាយតាមតម្រូវការឲ្យកែលម្អនោះ។

### <u>លក្ខខណ្ឌវិនិច្ឆ័យលើការកំណត់ក្របខណ្ឌការងាររបស់អង្គភាព</u>

១. ជាអង្គភាពដែលត្រូវបានបង្កើតដោយផ្អែកលើគោលបំណងគោលនយោបាយរបស់ក្រសួង ហើយស្ថិតក្នុងកម្រិតទី៣ នៃរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន និងត្រូវបានកំណត់មុខងារ និងភារកិច្ចព្រមទាំងបន្ទាត់គណនេយ្យភាពច្បាស់លាស់។

២. ជាអង្គភាពដែលមានសមិទ្ធកម្ម ឬលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយ នៅក្នុងកម្រិតដែលអាចវាស់វែងបាន។

៣. ជាអង្គភាពដែលមានទំហំសមស្រប (ទំហំការងារ ទំហំតម្រូវការបុគ្គលិកនិងទំហំតម្រូវការថវិកា) និងប្រកបដោយនិរន្តភាព។

**លក្ខខណ្ឌវិនិច្ឆ័យលើសមត្ថភាពរបស់អង្គភាព**

៤. ជាអង្គភាពដែលមានភាពជាម្ចាស់ និងការទទួលខុសត្រូវក្នុងការដឹកនាំ និងគ្រប់គ្រងប្រកបដោយគណនេយ្យភាព តម្លាភាពប្រសិទ្ធភាព និងភាពស័ក្តសិទ្ធិ។

៥. ជាអង្គភាពដែលមានសមត្ថភាពក្នុងការរៀបចំផែនការសកម្មភាពការងារ ផែនការយុទ្ធសាស្ត្រ និងថវិកាប្រចាំឆ្នាំ និងគ្រប់គ្រងការអនុវត្តផែនការសកម្មភាពការងារ និងគ្រប់គ្រងការអនុវត្តថវិកាប្រកបដោយប្រសិទ្ធភាព។

**លក្ខខណ្ឌវិនិច្ឆ័យលើសិទ្ធិទទួលថវិការបស់អង្គភាព**

៦. ជាអង្គភាពរដ្ឋដែលទទួលបានថវិកាតាមរយៈប្រព័ន្ធថវិការដ្ឋ។

៧. ជាអង្គភាពដែលទទួលបាន ឬគួរវិភាជថវិកាប្រចាំឆ្នាំ និងអាចទទួលខុសត្រូវលើការអនុវត្ត និងតាមដានថវិកាបាន។

## ក្រសួង: ________________________________________

| អង្គភាព/លក្ខខណ្ឌវិនិច្ឆ័យ | ស្របតាមលក្ខខណ្ឌ | មិនស្របតាមលក្ខខណ្ឌ | មូលហេតុដែលមិនស្របតាមលក្ខខណ្ឌ |
|---|---|---|---|
| **អង្គភាពទី១**: | | | |
| ១. ជាអង្គភាពដែលត្រូវបានបង្កើតដោយផ្អែកលើគោលបំណងគោលនយោបាយរបស់ក្រសួង ហើយស្ថិតក្នុងកម្រិតទី៣ នៃរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន និងត្រូវបានកំណត់មុខងារ និងភារកិច្ច ព្រមទាំងបន្ទាត់គណនេយ្យភាពច្បាស់លាស់។ | | | |
| ២. ជាអង្គភាពដែលមានសមិទ្ធកម្ម ឬលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយ នៅក្នុងកម្រិតដែលអាចវាស់វែងបាន។ | | | |
| ៣. ជាអង្គភាពដែលមានទំហំសមស្រប (ទំហំការងារ ទំហំតម្រូវការបុគ្គលិកនិងទំហំតម្រូវការថវិកា) និងប្រកបដោយនិរន្តភាព។ | | | |

| អង្គភាព/លក្ខខណ្ឌវិនិច្ឆ័យ | ស្របតាមលក្ខខណ្ឌ | មិនស្របតាមលក្ខខណ្ឌ | មូលហេតុដែលមិនស្របតាមលក្ខខណ្ឌ |
|---|---|---|---|
| ៤. ជាអង្គភាពដែលមានភាពជាម្ចាស់ និងការទទួលខុសត្រូវក្នុងការដឹកនាំនិងគ្រប់គ្រងប្រកបដោយគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងភាពស័ក្តសិទ្ធិ។ | | | |
| ៥. ជាអង្គភាពដែលមានសមត្ថភាពក្នុងការរៀបចំផែនការសកម្មភាពការងារ ផែនការយុទ្ធសាស្ត្រ និងថវិកាប្រចាំឆ្នាំ និងគ្រប់គ្រងការអនុវត្តផែនការសកម្មភាពការងារ និងគ្រប់គ្រងការអនុវត្តថវិកាប្រកបដោយប្រសិទ្ធភាព។ | | | |
| ៦. ជាអង្គភាពរដ្ឋដែលទទួលបានថវិកាតាមរយៈប្រព័ន្ធថវិការដ្ឋ។ | | | |
| ៧. ជាអង្គភាពដែលទទួលបាន ឬគួរវិភាជថវិកាប្រចាំឆ្នាំ និងអាចទទួលខុសត្រូវលើការអនុវត្ត និងតាមដានថវិកាបាន។ | | | |
| **អង្គភាពទី២:** | | | |
| ១. ជាអង្គភាពដែលត្រូវបានបង្កើតដោយផ្អែកលើគោលបំណងគោលនយោបាយរបស់ក្រសួង ហើយស្ថិតក្នុងកម្រិតទី៣ នៃរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន និងត្រូវបានកំណត់មុខងារ និងភារកិច្ច ព្រមទាំងបន្ទាត់គណនេយ្យភាពច្បាស់លាស់។ | | | |
| ២. ជាអង្គភាពដែលមានសមិទ្ធកម្ម ឬលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយ នៅក្នុងកម្រិតដែលអាចវាស់វែងបាន។ | | | |
| ៣. ជាអង្គភាពដែលមានទំហំសមស្រប (ទំហំការងារ ទំហំតម្រូវការបុគ្គលិកនិងទំហំតម្រូវការថវិកា) និងប្រកបដោយនិរន្តភាព។ | | | |
| ៤. ជាអង្គភាពដែលមានភាពជាម្ចាស់ និងការទទួលខុសត្រូវក្នុងការដឹកនាំ និងគ្រប់គ្រងប្រកបដោយគណ នេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងភាពស័ក្តសិទ្ធិ។ | | | |
| ៥. ជាអង្គភាពដែលមានសមត្ថភាពក្នុងការរៀបចំផែនការសកម្មភាពការងារ ផែនការយុទ្ធសាស្ត្រ និងថវិកាប្រចាំឆ្នាំ និងគ្រប់គ្រងការអនុវត្តផែនការសកម្មភាពការងារ និងគ្រប់គ្រងការអនុវត្តថវិកាប្រកបដោយប្រសិទ្ធភាព។ | | | |

| អង្គភាព/លក្ខខណ្ឌវិនិច្ឆ័យ | ស្របតាមលក្ខខណ្ឌ | មិនស្របតាមលក្ខខណ្ឌ | មូលហេតុដែលមិនស្របតាមលក្ខខណ្ឌ |
|---|---|---|---|
| ៦. ជាអង្គភាពរដ្ឋដែលទទួលបានថវិកាតាមរយៈប្រព័ន្ធថវិការដ្ឋ។ | | | |
| ៧. ជាអង្គភាពដែលទទួលបាន ឬគួរវិភាជថវិកាប្រចាំឆ្នាំ និងអាចទទួលខុសត្រូវលើការអនុវត្ត និងតាមដានថវិកាបាន។ | | | |
| **អង្គភាពទី៣:** | | | |
| ១. ជាអង្គភាពដែលត្រូវបានបង្កើតដោយផ្អែកលើគោលបំណងគោលនយោបាយរបស់ក្រសួង ហើយស្ថិតក្នុងកម្រិតទី៣ នៃរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន និងត្រូវបានកំណត់មុខងារ និងភារកិច្ច ព្រមទាំងបន្ទាត់គណនេយ្យភាពច្បាស់លាស់។ | | | |
| ២. ជាអង្គភាពដែលមានសមិទ្ធកម្ម ឬលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយ នៅក្នុងកម្រិតដែលអាចវាស់វែងបាន។ | | | |
| ៣. ជាអង្គភាពដែលមានទំហំសមស្រប (ទំហំការងារ ទំហំតម្រូវការបុគ្គលិកនិងទំហំតម្រូវការថវិកា) និងប្រកបដោយនិរន្តភាព។ | | | |
| ៤. ជាអង្គភាពដែលមានភាពជាម្ចាស់ និងការទទួលខុសត្រូវក្នុងការដឹកនាំ និងគ្រប់គ្រងប្រកបដោយគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងភាពស័ក្កសិទ្ធិ។ | | | |
| ៥. ជាអង្គភាពដែលមានសមត្ថភាពក្នុងការរៀបចំផែនការសកម្មភាពការងារ ផែនការយុទ្ធសាស្ត្រ និងថវិកាប្រចាំឆ្នាំ និងគ្រប់គ្រងការអនុវត្តផែនការសកម្មភាពការងារ និងគ្រប់គ្រងការអនុវត្តថវិកាប្រកបដោយប្រសិទ្ធភាព។ | | | |
| ៦. ជាអង្គភាពរដ្ឋដែលទទួលបានថវិកាតាមរយៈប្រព័ន្ធថវិការដ្ឋ។ | | | |
| ៧. ជាអង្គភាពដែលទទួលបាន ឬគួរវិភាជថវិកាប្រចាំឆ្នាំ និងអាចទទួលខុសត្រូវលើការអនុវត្ត និងតាមដានថវិកាបាន។ | | | |

# តារាងទី៥ ការរៀបចំផែនការសកម្មភាពសម្រាប់កែលម្អ

## (ជំហានទី៤)

គោលបំណងនៃតារាងទី៥ គឺដើម្បីរៀបចំរចនាសម្ព័ន្ធអង្គភាពថវិកា ដែលបានស្នើឡើងសម្រាប់ក្រសួង ដោយយកតាមព័ត៌មានដែលបានផ្តល់តាមរយៈការបំពេញតារាងទី១ ដល់ទី៤។ ក្នុងការបំពេញតារាង គួរតែយកតាមរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន (តួលេខទី១) ដែលមាននៅក្នុងផ្នែក២.៣ នៃគោលការណ៍ណែនាំ។ នៅក្នុងតារាងនេះ នឹងមានបង្ហាញពីកម្រិតទី៣ របស់ស្ថាប័នបច្ចុប្បន្ន ដែលបំពេញតាមលក្ខខណ្ឌវិនិច្ឆ័យទាំងអស់ ឬមានអាណត្តិកិច្ច មុខងារ និងលទ្ធផលក្នុងឆ្នាំច្បាស់លាស់ ប៉ុន្តែប្រហែលជាត្រូវធ្វើការកែលម្អដើម្បីឲ្យត្រូវតាម ទាំងស្រុងជាមួយនឹងលក្ខខណ្ឌវិនិច្ឆ័យផ្សេងៗទៀត ហើយកម្រិតទី៣ របស់ស្ថាប័ននីមួយៗ គួរតែបានភ្ជាប់ទៅនឹង កម្រិតទី២ (អគ្គនាយក)។គ្រប់អង្គភាពទាំងអស់គួរតែភ្ជាប់ទៅនឹងគោលបំណងគោលនយោបាយ និងកម្មវិធី-យុទ្ធសាស្ត្រអាទិភាព ឬអនុកម្មវិធី ដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង។ គ្រប់កម្រិតទី៣ របស់ស្ថាប័នទាំងអស់ ដែលមិនបានបំពេញតាមលក្ខខណ្ឌវិនិច្ឆ័យ សូមចុះនៅក្នុងកន្លែងដែលស្ថិតនៅ ខាងក្រោម តារាងនេះ។

## ក្រសួង: ________________________________

| អង្គភាពដែលបានវាយតម្លៃ | សូមរៀបចំសកម្មភាពដែលត្រូវកែលម្អ | | |
|---|---|---|---|
| | ផ្នែក<br>ការកំណត់ក្របខណ្ឌការងាររបស់អង្គភាព<br>(១-៣) | ផ្នែក<br>សមត្ថភាពរបស់អង្គភាព<br>(៤-៥) | ផ្នែក<br>សិទ្ធិទទួលថវិការបស់អង្គភាព<br>(៦-៧) |
| **អង្គភាពដែលស្របតាមលក្ខខណ្ឌវិនិច្ឆ័យទាំង៧**: | | | |
| | | | |
| | | | |
| **អង្គភាពដែលមិនសមស្របតាមលក្ខខណ្ឌវិនិច្ឆ័យទាំង៧:** (សូមរៀបចំតាមលំដាប់នៃកម្រិតស្របតាមលក្ខខណ្ឌវិនិច្ឆ័យ ដោយដាក់អង្គភាពដែលមានកម្រិតមិនស្របតិចជាងគេនៅខាងលើ) | | | |
| | | | |
| | | | |
| | | | |

## តារាងទី៦ របាយការណ៍ស្តីពីការស្នើសុំអង្គភាពថវិការបស់ក្រសួង ស្ថាប័ន
## (ជំហានទី៥)

គោលបំណងនៃតារាងទី៦នេះ គឺសម្រាប់បូកសរុបលទ្ធផលពីជំហានទី១ ដល់ទី៤ ដើម្បី (ក) កំណត់អ្នកទទួលខុសត្រូវ និងពេលវេលាសម្រាប់ការអនុវត្តសកម្មភាពដែលត្រូវកែលម្អ (ខ)កំណត់អង្គភាពដែលអាចក្លាយជាអង្គភាពថវិកានៅឆ្នាំ២០១៥(គ)កំណត់បណ្តាបញ្ហាប្រឈមដែលក្រសួង ស្ថាប័នយល់ថានឹងអាចកើតមានឡើងក្នុងពេលដាក់ឲ្យអនុវត្តឆ្នាំ២០១៥។

### ក្រសួង: ________________________________________

### ក. ការកំណត់អ្នកទទួលខុសត្រូវ និងពេលវេលាសម្រាប់ការអនុវត្តសកម្មភាពដែលត្រូវកែលម្អ

| សកម្មភាពដែលត្រូវកែលម្អ | អ្នកទទួលខុសត្រូវ/ពេលវេលា/ផ្សេងៗ | | |
|---|---|---|---|
| | អ្នកទទួលខុសត្រូវ | ពេលវេលា | ផ្សេងៗ |
| ផ្នែកការកំណត់ក្របខណ្ឌការងាររបស់អង្គភាព | | | |
| | | | |
| | | | |
| ផ្នែកសមត្ថភាពរបស់អង្គភាព | | | |
| | | | |
| | | | |
| ផ្នែកសិទ្ធិទទួលថវិការបស់អង្គភាព | | | |
| | | | |
| | | | |

## ខ. ការកំណត់អង្គភាពដែលអាចក្លាយជាអង្គភាពថវិកានៅឆ្នាំ២០១៥

១.........................................................................................................

២.........................................................................................................

៣................................................................................................................

................................................................................................................

................................................................................................................

................................................................................................................

............

## គ. បណ្តាបញ្ហាប្រឈមដែលក្រសួង ស្ថាប័នយល់ថានឹងអាចកើតមានឡើងក្នុងពេលដាក់ឲ្យអនុវត្តឆ្នាំ ២០១៥

១.........................................................................................................

២.........................................................................................................

៣................................................................................................................

................................................................................................................

.............................................................................................

## ឃ. តារាងភ្ជាប់មកជាមួយ

- តារាងទី១: រចនាសម្ព័ន្ធគោលនយោបាយរបស់ក្រសួង ស្ថាប័ន
- តារាងទី២: រចនាសម្ព័ន្ធគ្រប់គ្រងក្រសួង ស្ថាប័ន
- តារាងទី៣: ការផ្សារភ្ជាប់រចនាសម្ព័ន្ធគ្រប់គ្រង ទៅនឹងរចនាសម្ព័ន្ធគោលនយោបាយរបស់ក្រសួង ស្ថាប័ន
- តារាងទី៤: ការវាយតម្លៃតាមលក្ខខណ្ឌវិនិច្ឆ័យរបស់អង្គភាពថវិកា
- តារាងទី៥: ការរៀបចំផែនការសកម្មភាពសម្រាប់កែលម្អ
- តារាងទី៦: របាយការណ៍ស្តីពីការស្នើសុំអង្គភាពថវិការបស់ក្រសួង ស្ថាប័ន

**រៀបចំដោយៈ**

..........................................................................................................................................

ហត្ថលេខា និងឈ្មោះ

**អនុម័តដោយៈ**

..........................................................................................................................................

ហត្ថលេខា និងឈ្មោះ

**សូមផ្តល់ព័ត៌មានសម្រាប់ទំនាក់ទំនងពាក់ព័ន្ធនឹងឯកសារនេះ**

ឈ្មោះ ......................................................................

តួនាទី ......................................................................

លេខទូរស័ព្ទ ..............................................................

សារអេឡិចត្រូនិច ......................................................

## ឧបសម្ព័ន្ធ២ ក្របខណ្ឌនៃការទទួលខុសត្រូវរវាងនាយកដ្ឋានហិរញ្ញវត្ថុ និងអង្គភាពថវិកា

តារាងខាងក្រោមនេះ បង្ហាញអំពីក្របខណ្ឌការងារ និងការទទួលខុសត្រូវរវាងនាយកដ្ឋានហិរញ្ញវត្ថុ និងនាយកដ្ឋានជំនាញ (ឬអង្គភាពថវិកា) ដែលកំពុងអនុវត្តបច្ចុប្បន្ន និងដែលត្រូវកែលម្អសម្រាប់ការអនុវត្តអង្គភាពថវិកាសាកល្បងក្នុងដំណាក់កាលទី១ នៅឆ្នាំ២០១៥។ ការកែលម្អនៅដំណាក់កាលនេះ ផ្តោតទៅលើការធ្វើឲ្យមានភាពច្បាស់លាស់រវាងមុខងារ ភារកិច្ច ការទទួលខុសត្រូវ និងសិទ្ធិអំណាច ក្នុងការប្រើប្រាស់ថវិកា និងការគ្រប់គ្រងថវិការវាងនាយកដ្ឋានហិរញ្ញវត្ថុ (អ្នកគ្រប់គ្រងថវិកា) និងនាយកដ្ឋានជំនាញ (អង្គភាពថវិកា ឬអ្នកប្រើប្រាស់ថវិកា) គឺក្នុងគោលដៅបង្កើនតម្លាភាព គណនេយ្យភាព និងប្រសិទ្ធិភាពក្នុងការរៀបចំ និងការអនុវត្តថវិកា។

| | **បច្ចុប្បន្ន** | **ត្រូវកែលម្អសម្រាប់ការអនុវត្តអង្គភាពថវិកា** |
|---|---|---|
| | **ការរៀបចំថវិកា** | |
| **នាយកដ្ឋាន ហិរញ្ញវត្ថុ** | ភាគច្រើននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ រៀបចំ និងគ្រប់គ្រងថវិកាប្រចាំឆ្នាំរបស់ក្រសួងការងារទាំង នោះរួមមានៈ<br>• ការរៀបចំផែនការយុទ្ធសាស្រ្តថវិកា<br>• ការរៀបចំថវិកាប្រចាំឆ្នាំ | មានតួនាទីដើម្បីរៀបចំគោលការណ៍ នីតិវិធី ការសម្រប សម្រួល និងបូកសរុបការរៀបចំថវិកាប្រចាំឆ្នាំៈ<br>• រៀបចំគោលការណ៍ និងនីតិវិធីសម្រាប់ការរៀបចំថវិកា។<br>• បូកសរុបផែនការយុទ្ធសាស្រ្ត និងការរៀបចំ ថវិកាប្រចាំឆ្នាំ ដែលបានស្នើឡើងដោយអង្គភាពថវិកា។<br>• រៀបចំផែនការយុទ្ធសាស្រ្តថវិកា និងថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័នសម្រាប់ក្រុមការងារថវិកាដើម្បីផ្តល់យោបល់ មុនពេលដាក់បញ្ជូនទៅឱ្យ ប្រធានស្ថាប័នពិនិត្យ និងសម្រេច។ |

| | បច្ចុប្បន្ន | ត្រូវកែលម្អសម្រាប់ការអនុវត្តអង្គភាពថវិកា |
|---|---|---|
| **អង្គភាពថវិកា** | ភាគច្រើននាយកដ្ឋានផ្សេងៗមិនមានឱកាសចូលរួម ក្នុងការរៀបចំ និង គ្រប់គ្រងថវិកាប្រចាំឆ្នាំទេ។ ប៉ុន្តែ ការចូលរួមក្នុងការរៀបចំ និង គ្រប់គ្រងថវិកាប្រចាំឆ្នាំ បានចាប់ផ្តើមធ្វើនៅក្រសួងមួយចំនួន ចាប់តាំងពី នាយកដ្ឋានទាំងនោះ ត្រូវបានតម្រូវឱ្យមានការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងបង្កើតជាក្រុមការងារថវិកាមក។ | មានតួនាទីដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាប្រចាំឆ្នាំសម្រាប់ដាក់ឱ្យថ្នាក់ដឹកនាំដើម្បីពិនិត្យ និងសម្រេចក្នុងការៈ<br>• រៀបចំផែនការយុទ្ធសាស្ត្រថវិកាឱ្យស្របតាមការណែនាំរបស់នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ។<br>• រៀបចំថវិកាប្រចាំឆ្នាំរបស់ខ្លួនឱ្យស្របតាមការណែនាំរបស់នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ។ |
| | **ការអនុវត្តថវិកា** | |
| **នាយកដ្ឋាន ហិរញ្ញវត្ថុ** | មានតួនាទីដើម្បីអនុវត្តថវិកាទាំងស្រុងរបស់ក្រសួងៈ<br>• ការរៀបចំផែនការចំណូល និង ចំណាយសាច់ ប្រាក់<br>• អនុវត្តចំណូលចំណាយ- | មានតួនាទីរៀបចំគោលការណ៍ និងនីតិវិធីផ្សេងៗសម្រាប់សម្របសម្រួល និងផ្តល់ការគាំទ្រដល់អង្គភាពថវិកាក្នុងការបូកសរុបការអនុវត្តថវិការបស់ខ្លួនៈ<br>• ការអនុវត្ត និងការគ្រប់គ្រងការអនុវត្តថវិការបស់ក្រសួងស្ថាប័ន<br>• រៀបចំគោលការណ៍ និងនីតិវធីសម្រាប់រៀបចំផែនការអនុវត្តផែនការសាច់ប្រាក់ចំណូល ចំណាយ<br>• បូកសរុប រៀបចំ និងពិនិត្យតាមដានផែនការសាច់ប្រាក់ចំណូល ចំណាយរបស់ក្រសួង។<br>• ផ្តល់ការគាំទ្រ និងសម្រប សម្រួលដល់ការអនុវត្តថវិកាទៅគ្រប់អង្គភាពថវិកា។ |

| | បច្ចុប្បន្ន | ត្រូវកែលម្អសម្រាប់ការអនុវត្តអង្គភាពថវិកា |
|---|---|---|
| **អង្គភាពថវិកា** | ភាគច្រើននាយកដ្ឋានផ្សេងៗមិនមានឱកាសចូលរួម ក្នុងការរៀបចំផែនការសាច់ប្រាក់ចំណូល ចំណាយទេ។ លើសពីនេះទៅទៀត នាយកដ្ឋានខ្លះ មិនបានរៀបចំផែនការសកម្មភាពរបស់ខ្លួនដើម្បីផ្តល់ជូនទៅនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុទេ។ | មានតួនាទីរៀបចំ និងអនុវត្ត សកម្មភាពរបស់ខ្លួនតាមទិសដៅរបស់រដ្ឋមន្ត្រី ឬប្រធានស្ថាប័នរួមមាន៖<br>• ការគ្រប់គ្រង ការទទួលខុសត្រូវ ដែលបានផ្តល់ឱ្យ។<br>• រៀបចំផែនការសាច់ប្រាក់ ចំណូល ចំណាយ ដើម្បីឲ្យក្រសួងពិនិត្យ និងសម្រេច។<br>• ត្រួតពិនិត្យ និងតាមដាន ផែនការសកម្មភាពរបស់ខ្លួន ដោយផ្តោតទៅលើប្រសិទ្ធិភាព និងភាពសក្តិសិទ្ធនៃការចំណាយរបស់ខ្លួន។<br>• បញ្ជាក់ពីការកែតម្រូវថវិកា និងការផ្តួចផ្តើមស្នើសុំធ្វើនិយ័តកម្មទៅនាយកដ្ឋានហិរញ្ញវត្ថុរបស់ក្រសួង។<br>• លើកឡើងពីសំណើនៃការទិញ និងការធានាចំណាយផ្សេងៗ ឱ្យមានសង្គតិភាពជាមួយនឹងបទបញ្ជាផ្សេងៗ និងការគ្រប់គ្រប់របស់នាយកដ្ឋានហិរញ្ញវត្ថុ និង នាយកដ្ឋានលទ្ធកម្ម។<br>• អង្គភាពថវិកា គួរបង្កើតឱ្យមានគណនីរដ្ឋទេយ្យរបស់ខ្លួនផ្ទាល់។ |
| | **ការពិនិត្យ តាមដានការអនុវត្តថវិកា** | |
| **នាយកដ្ឋានហិរញ្ញវត្ថុ** | វាហាក់ដូចជាមិនច្បាស់លាស់ទេ។ ប៉ុន្តែភាគច្រើនធ្វើការពិនិត្យតាមដាន និង ធ្វើរបាយការណ៍ហិរញ្ញវត្ថុ។ | មានតួនាទីគ្រប់គ្រង និងពិនិត្យ តាមដានការអនុវត្តថវិកាទាំងស្រុងរបស់ក្រសួង៖<br>• រៀបចំប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងសម្រាប់ក្រសួង (គោលការណ៍ នីតិវិធី យន្តការ និងប្រព័ន្ធរបាយការណ៍)<br>• ពិនិត្យតាមដានការអនុវត្តថវិកានៃគ្រប់អង្គភាពថវិកាទាំងអស់ |

| | បច្ចុប្បន្ន | ត្រូវកែលម្អសម្រាប់ការអនុវត្តអង្គភាពថវិកា |
|---|---|---|
| | | រួមមានៈ ការកំណត់ និងដំណើរការនិយ័តកម្ម សម្រាប់សម្រេចដោយរដ្ឋមន្ត្រី ឬថ្នាក់ដឹកនាំខ្ពស់ បន្ទាប់ដើម្បីឱ្យមានសង្គតិភាពទៅនឹងបទបញ្ញាផ្សេងៗរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។<br>• រៀបចំបូកសរុបរបាយការណ៍អនុវត្តថវិការបស់អង្គភាពថវិកា និង ការអនុវត្តថវិការបស់ក្រសួង។ |
| **អង្គភាពថវិកា** | វាហាក់ដូចជាមិនច្បាស់លាស់ទេ។ ប៉ុន្តែ ភាគច្រើន ធ្វើការពិនិត្យតាមដាន និងធ្វើរបាយការណ៍ស្តីពីផែនការសកម្មភាពរបស់ខ្លួននៅពេលចាំបាច់។ | មានតួនាទីគ្រប់គ្រង និងពិនិត្យ តាមដានការនុវត្តន៍ថវិកា និងសកម្មភាពការងាររបស់ខ្លួនដែលបានផ្តល់ដោយក្រសួងៈ<br>• រៀបចំប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួនឱ្យស្របតាមការណែនាំរបស់ក្រសួង<br>• ពិនិត្យតាមដានការអនុវត្តថវិកា និង សកម្មភាពការងាររបស់ខ្លួនឱ្យស្របតាមបទបញ្ញាផ្សេងៗរបស់នាយកដ្ឋានហិរញ្ញវត្ថុ និង ឱ្យមានសង្គតិភាពជាមួយនឹងការ ត្រួតពិនិត្យថវិកា។<br>• រៀបចំរបាយការណ៍ស្តីពីការអនុវត្តថវិកា និងសមិទ្ធកម្មនៃសកម្មភាពការងាររបស់ខ្លួនសម្រាប់ក្រសួង។ |